ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គជអប

NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤

# របស់ គ.ជ.អ.ប.

ខែមករា ឆ្នាំ២០២៤

# អារម្ភកថា

**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺជាកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏មានសារៈសំខាន់មួយរបស់រាជរដ្ឋាភិបាលដែលបានរៀបចំ និងដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០១។ កំណែទម្រង់នេះមានគោលបំណងដ៏ទូលំទូលាយក្នុងការចូលរួមថែរក្សានូវសុខសន្តិភាព និងស្ថិរភាពនយោបាយ ការបង្កើតមូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យ និងអភិបាលកិច្ចនៅមូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ សំដៅចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាព និងការលើកកម្ពស់គុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ ដើម្បីធានាដល់ការអនុវត្តកម្មវិធីកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើជាផែនទីបង្ហាញផ្លូវដែលក្នុងនោះកម្មវិធីជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី១ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១០ និងបានបញ្ចប់ការអនុវត្តនៅចុងឆ្នាំ២០២០កន្លងមកនេះ ដោយសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន និងបញ្ហាសេសសល់មួយចំនួនដែលត្រូវបន្តដោះស្រាយ។ ផ្អែកលើមូលដ្ឋាននេះ និងដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការបែងចែកផលប្រយោជន៍ជូនប្រជាពលរដ្ឋប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ (កជទី២)។

ដើម្បីធានាដល់ការអនុវត្តកជទី២នេះឱ្យសម្រេចបាននូវសមិទ្ធផល និងលទ្ធផលរំពឹងទុកនានាដែលបានកំណត់ដោយរលូន មានភាពបត់បែនប្រកបដោយនវានុវត្តន៍ និងមានប្រសិទ្ធភាពខ្ពស់ កជទី២តម្រូវឱ្យមានផែនការអនុវត្តសម្រាប់រយៈពេល៥ឆ្នាំលើកទី១ និងផែនការអនុវត្ត៥ឆ្នាំលើកទី២ ព្រមទាំងតម្រូវឱ្យមានផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនីមួយៗ (ផ.ស.ថ.)។

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤របស់គ.ជ.អ.ប. គឺជាផែនការឆ្នាំទី៤នៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ និងមានគោលដៅសំខាន់គឺការពង្រឹងរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានការពាក់ព័ន្ធទៅគ្រប់វិស័យគ្រប់ស្ថាប័ន និងគ្រប់ការដ្ឋានកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល អាស្រ័យហេតុនេះ ដើម្បីធានាដល់ការសម្រេចនូវគោលដៅខាងលើនេះ ចាំបាច់ទាមទារឱ្យមានការចូលរួមចំណែកយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានា ដោយផ្តោតលើអភិក្រម **រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ**សំដៅធ្វើឱ្យប្រជាពលរដ្ឋទទួលបានសេវាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។ អាស្រ័យហេតុនេះ ផ.ស.ថ. ឆ្នាំ២០២៤ ត្រូវបានរៀបចំដោយមានការចូលរួម

និងប្រឹក្សាយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័នអនុវត្ត និងភាគីពាក់ព័ន្ធនានា ដើម្បីធានាដល់ការទទួលខុសត្រូវ និងពង្រឹងភាពជាម្ចាស់ក្នុងការគ្រប់គ្រង និងការអនុវត្តផែនការនេះ ស្របតាមតួនាទី និងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធនីមួយៗ។ ជាមួយគ្នានេះដែរ ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ ក៏ត្រូវពង្រឹងកិច្ចសហការ និងការសម្របសម្រួលជាមួយកម្មវិធីកំណែទម្រង់អភិបាលកិច្ច និងកម្មវិធីកំណែទម្រង់វិស័យនានា ដើម្បីធានាការសម្រេចបាននូវលទ្ធផលរំពឹងទុកនានាដែលបានកំណត់ក្នុងផែនការនេះ។

ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលនូវផ្នែកសំខាន់ៗដូចជា លទ្ធផលរំពឹងទុកជាអាទិភាពពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវសម្រេចក្នុងឆ្នាំ២០២៤ ការគ្រប់គ្រងហានិភ័យ និងបែបផែនសម្រាប់អនុវត្ត និងគ្រប់គ្រង ផ.ស.ថ.។ ជាពិសេស ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលនូវក្របខ័ណ្ឌលទ្ធផលដែលសង្ខេបអំពីលទ្ធផលរំពឹងទុក សូចនាករ ចំណុចដៅ និងក្របខ័ណ្ឌពេលវេលាដែលត្រូវសម្រេចលទ្ធផលរំពឹងទុកទាំងនោះតាមសមាសភាគនីមួយៗ។ ក្របខ័ណ្ឌលទ្ធផលនេះ គឺជាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍។

ជាការពិត ការអនុវត្ត ផ.ស.ថ. អាចជួបប្រទះនូវបញ្ហាប្រឈម ហានិភ័យ តម្រូវការចាំបាច់នានា។ អាស្រ័យហេតុនេះ ស្ថាប័នអនុវត្តទាំងអស់អាចពិនិត្យ និងកែសម្រួល ផ.ស.ថ. របស់ខ្លួនតាមការចាំបាច់ស្របតាមនីតិវិធី ដែលបានកំណត់ និងដោយមានការសម្របសម្រួល និងការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាម គ.ជ.អ.ប. ខ្ញុំមានសុទិដ្ឋិនិយមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល អ្នកពាក់ព័ន្ធនានា ព្រមទាំងប្រជាពលរដ្ឋនឹងបន្តចូលរួមក្នុងកិច្ចដំណើរការអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យមានការរីកចម្រើនទៅមុខប្រកបដោយផ្លែផ្កា និងគុណតម្លៃ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋយើងក្នុងការរស់នៅប្រកបដោយសុខសន្តិភាព មានសិទ្ធិសេរីភាព និងប្រជាធិបតេយ្យ មានជីវភាពរស់នៅល្អប្រសើរ មានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ទទួលបាននូវសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព យុត្តិធម៌ បរិយាប័ន្ន និងសមធម៌សង្គម។

ថ្ងៃសុក្រ ៩ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

# មាតិកា

**អារម្ភកថា** ........................................ i
**បញ្ជីតារាង** ........................................ v
**បញ្ជីអក្សរកាត់** ........................................ vi
**I. ទិដ្ឋភាពទូទៅ** ........................................ **៧**
ក. សេចក្តីផ្តើម ........................................ ៧
ខ. សមិទ្ធផល និងបញ្ហាប្រឈម ........................................ ៨
គ. កិច្ចដំណើរការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤. ........................................ ១៣
ឃ. រចនាសម្ព័ន្ធ ផ.ស.ថ. ........................................ ១៣
**II. សមាសភាគនៃ ផ.ស.ថ. ឆ្នាំ២០២៤** ........................................ **១៥**
**សមាសភាគទីមួយ ÷ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** ........................................ **១៥**
ក. សមិទ្ធផលរំពឹងទុក ........................................ ១៥
ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព ........................................ ១៥
**សមាសភាគទីពីរ ÷ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** ........................................ **២៥**
ក. សមិទ្ធផលរំពឹងទុក ........................................ ២៥
ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព ........................................ ២៥
**សមាសភាគទីបី ÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ........................................ **៣៦**
ក. សមិទ្ធផលរំពឹងទុក ........................................ ៣៦
ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព ........................................ ៣៦
**សមាសភាគទីបួន ÷ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ** ........................................ **៤៥**
ក. សមិទ្ធផលរំពឹងទុក ........................................ ៤៥
ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព ........................................ ៤៥
**សមាសភាគទីប្រាំ ÷ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** ........................................ **៥៦**
ក. សមិទ្ធផលរំពឹងទុក ........................................ ៥៦
ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព ........................................ ៥៦
**III. ថវិកាសម្រាប់គាំទ្រ ផ.ស.ថ. ឆ្នាំ២០២៤** ........................................ **៦៣**
ក. ផែនការចំណាយរួម ........................................ ៦៣
ខ. ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........................................ ៦៣
**IV. ការគ្រប់គ្រង ផ.ស.ថ. ឆ្នាំ២០២៤** ........................................ **៦៩**
ក. ការគ្រប់គ្រង និងការអនុវត្តសកម្មភាព ........................................ ៦៩

ខ. ការគ្រប់គ្រង និងការអនុវត្តថវិកា ........................................................ ៦៩
គ. ការតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ .......................................... ៧០

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** តារាងក្របខ័ណ្ឌលទ្ធផលនៃ ផ.ស.ថ. ឆ្នាំ២០២៤ .............................. ៧២
**ឧបសម្ព័ន្ធទី២៖** តារាងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ ................................. ៩០
**ឧបសម្ព័ន្ធទី៣៖** តារាងការគ្រប់គ្រងហានិភ័យ ...................................................... ១២១

# បញ្ជីតារាង

តារាងទី១ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីមួយ ....................................២០
តារាងទី២ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីមួយ..........................................២១
តារាងទី៣ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីពីរ .......................................៣០
តារាងទី៤ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីពីរ ..........................................៣២
តារាងទី៥ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបី..........................................៣៩
តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីបី ............................................៤១
តារាងទី៧ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបួន .......................................៤៩
តារាងទី៨ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីបួន ..........................................៥១
តារាងទី៩ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីប្រាំ.......................................៥៩
តារាងទី១០ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីប្រាំ .....................................៦០
តារាងទី១១ ៖ ផែនការចំណាយសរុបតាមសមាសភាគសម្រាប់ឆ្នាំ២០២៤ .......................៦៣
តារាងទី១២ ៖ ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៤ .......................៦៤
តារាងទី១៣ ៖ ផែនការថវិកាចំណាយសរុបទៅលើសកម្មភាពស្នូលនៃកំណែទម្រង់............៦៥
តារាងទី១៤ ៖ ផែនការថវិកាចំណាយតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ.........៦៦
តារាងទី១៥ ៖ ថវិកាកម្ចីនៃគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍ....................................៦៧
តារាងទី១៦ ៖ ថវិកាជំនួយឥតសំណងនៃគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍ ...............៦៨

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ ពីឆ្នាំ ២០១០ ដល់ឆ្នាំ២០២០ |
| ផអ៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំនៃ កជទី១ |
| ផអ៣ទី៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំ (២០១៨-២០២០) ដំណាក់កាលទី៣នៃ កជទី១ |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ (២០២១-២០២៥) ដំណាក់កាលទី១នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ផែនការអនុវត្តគណនេយ្យភាពសង្គម |
| JAAP | ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម |
| NASLA/ADB | គម្រោងគាំទ្រសាលាជាតិរដ្ឋបាលមូលដ្ឋាន |
| UNICEF | មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ |
| STARD/UNDP | គម្រោងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលពន្លឺព្រះអាទិត្យសម្រាប់វិស័យកសិកម្ម និង អភិវឌ្ឍន៍ជនបទនៅកម្ពុជា |
| WRP/UNCDF | នវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ |
| CNP/WB | គម្រោងអាហារូបត្ថម្ភនៅកម្ពុជា |
| ISD/GIZ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា |
| STAD/UNDP | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ ប្រជាពលរដ្ឋ |
| SCIF/ GCF | ការរៀបចំយន្តការ និងសៀវភៅណែនាំស្តីពីមូលនិធិវិនិយោគប្រែប្រួលអាកាសធាតុរដ្ឋបាលថ្នាក់ ក្រោមជាតិ |
| CSOs | អង្គការសង្គមស៊ីវិល |

# I. និដ្ឋភាពទូទៅ

## ក. សេចក្តីផ្តើម

កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១០-២០២០) ត្រូវបានអនុវត្តបញ្ចប់នៅក្នុងឆ្នាំ២០២០ ដោយសម្រេចបានសមិទ្ធផលធំៗជាច្រើនក្នុងការពង្រឹង និងលើកកម្ពស់អភិបាលកិច្ច និងប្រជាធិបតេយ្យនៅមូលដ្ឋាន ប្រជាពលរដ្ឋមានសិទ្ធិអំណាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានានៅមូលដ្ឋានក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន ប្រជាពលរដ្ឋទទួលបានសេវាកាន់តែល្អប្រសើរ និងរស់នៅប្រកបដោយសុខក្សេមក្សាន្តក្រោមម្លប់សន្តិភាព និងការអភិវឌ្ឍ។ ដើម្បីបន្តកំណែទម្រង់ដ៏មានសារៈសំខាន់នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវឯកសារទស្សនទានស្តីពីការរៀបចំកម្មវិធីជាតិដំណាក់កាលទី២ ដែលជាគោលការណ៍ណែនាំតម្រង់ទិសដ៏សំខាន់ សម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០។ ផ្អែកលើឯកសារទស្សនទាននេះ គ.ជ.អ.ប. បានដឹកនាំ និងសម្របសម្រួលការរៀបចំតាក់តែងកម្មវិធីជាតិ ដំណាក់កាលទី២ (ហៅថា **កជទី២**) ដោយមានការចូលរួម និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ជាលទ្ធផល ឯកសារកជទី២ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១។ ក្នុងការអនុវត្ត កជទី២នេះ តម្រូវឱ្យមានការរៀបចំផែនការអនុវត្តជាពីរដំណាក់កាលពោលគឺ ដំណាក់កាលទី១ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០២៥ (ផអ៥ទី១) និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០២៦ដល់ឆ្នាំ២០៣០ (ផអ៥ទី២)។

លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំ និងសម្របសម្រួលដំណើរការរៀបចំតាក់តែង ផអ៥ទី១ ដោយមានការចូលរួម និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ឯកសារ ផអ៥ទី១ ត្រូវបានអនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃអង្គារ ១២រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។ ផអ៥ទី១ ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន លក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈ៖

- ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈ និងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងតាមបច្ចេកវិទ្យាឌីជីថល
- ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កើនធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបែងចែកថវិកាប្រកបដោយតម្លាភាព អាចព្យាករណ៍បាន និងធានាដល់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាង



ψ

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងការអនុវត្តថវិការបស់ខ្លួន

- ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដើម្បីជំរុញ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើសេចក្ដីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៤ (ផ.ស.ថ.) គឺជាផែនការសកម្មភាពឆ្នាំទី៤នៃការអនុវត្ត ផអ៥ទី១។ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ផ្ដោតលើការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងធ្វើទំនើបកម្មនូវយន្តការនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមជូនប្រជាពលរដ្ឋ។

ផ.ស.ថ. ឆ្នាំ២០២៤ រៀបរាប់អំពីសកម្មភាពលម្អិតនៃសកម្មភាពជាអាទិភាពរបស់ផអ៥ទី១ដែលត្រូវសម្រេចក្នុងឆ្នាំ២០២៤។ សូចនាករសំខាន់ៗនៃសកម្មភាពលម្អិតទាំងនេះ ត្រូវបានកំណត់តាមសកម្មភាពជាអាទិភាពដែលបានរៀបចំដោយសង្ខេបក្នុងតារាងក្របខ័ណ្ឌលទ្ធផល (ឧបសម្ព័ន្ធទី១) រួមបញ្ចូលនូវព័ត៌មានអំពីសូចនាករ ទិន្នន័យដើមគ្រា និងចំណុចដៅតាមឆមាសនីមួយៗ។ ក្របខ័ណ្ឌលទ្ធផលនេះ គឺជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យ វាយតម្លៃ និងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្ត ផ.ស.ថ. ជូន គ.ជ.អ.ប. និងភាគីពាក់ព័ន្ធនានា។ សកម្មភាពលម្អិតទាំងអស់រួមបញ្ចូលថវិកា ក្របខ័ណ្ឌពេលវេលាអនុវត្តតាមឆមាស និងស្ថាប័នទទួលខុសត្រូវមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី២អំពីតារាងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤។

ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ត្រូវអនុវត្តដោយក្រសួង ស្ថាប័នចំនួន២១ រដ្ឋបាលរាជធានី ខេត្តចំនួន២៥ រដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន២០៨ រដ្ឋបាលឃុំ សង្កាត់ចំនួន១.៦៥២ សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងដោយមានការចូលរួមពីដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន ព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀត។

## ២. សមិទ្ធផល និងបញ្ហាប្រឈម

សមិទ្ធផលសំខាន់ៗនៃការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៣ មានបរិយាយទៅតាមសមាសភាគនីមួយៗ ដូចខាងក្រោម ៖

**សមាសភាគទី១ ៖ ស្ដីពីការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់** សម្រេចបានសមិទ្ធផលសំខាន់ៗមានដូចជា (១) ការពិនិត្យ និងអនុម័តលើរបាយការណ៍ស្ដីពីលទ្ធផលនៃការសិក្សាវាយតម្លៃមុខងារអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការដាក់ចេញអនុក្រឹត្យស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (២) ការដាក់ចេញនូវអនុក្រឹត្យស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ អនុក្រឹត្យស្ដីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ និងអនុក្រឹត្យស្ដីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូន

មូលនិធិរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ពីឆ្នាំ២០២៤-២០២៨ (៣) សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិត្រូវបានដាក់បញ្ចូលទៅក្នុងក្រមបរិស្ថាននិងធនធានធម្មជាតិ និងបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីព្រៃឈើបញ្ជូនទៅក្រសួងយុត្តិធម៌ដើម្បីពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសបញ្ញត្តិ (៤) លេខាធិការដ្ឋាននៃកម្មវិធីកំណែទម្រង់៣បូក១ បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅសម្រាប់បន្តអនុវត្តសកម្មភាពរួមគ្នានៃកំណែទម្រង់ទាំង៤ និងបានចូលរួមទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅសាធារណរដ្ឋកូរ៉េ ដែលដឹកនាំរៀបចំដោយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (៥) ផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប. ឆ្នាំ២០២៣ ត្រូវបានរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះសកម្មភាពជាអាទិភាពចំនួន៦៣ ស្មើនឹង៨៣% នៃសកម្មភាពសរុបត្រូវបានអនុវត្ត ហើយសេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២០ និងរដ្ឋបាលរាជធានី ខេត្តចំនួន២៥ ត្រូវបានអនុម័ត និងអនុវត្ត (៦) គម្រោង និងកម្មវិធីដាច់ដោយឡែកចំនួន១៣ បានចូលរួមក្នុងកម្មវិធីកំណែទម្រង់នេះ មានដូចជា ៖ គម្រោង WB/ISAF, GIZ/ISD, UNICEF (វិស័យសេវាសង្គម និងកិច្ចគាំពារកុមារ), UNCDF/LGCC-WRP, UNDP/CCCA, UNDP/STARD, STAR, ADB/SNIF, ADB/NASLA, ADB/TSDD, GCF/READINESS, WB/CNP (៧) បានរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មានអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដល់ស្ថាប័នសារព័ត៌មាននានា (៨) បានបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រី និងអង្គភាពពាក់ព័ន្ធនានាអំពីការងារយេនឌ័រ និងការលើកកម្ពស់ស្ត្រីទទួលបានមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះថ្នាក់រាជធានី ខេត្ត ចំនួន២៧,៥១ % និងរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន២៣,៥៨ %។

**សមាសភាគទី២ ៖ ស្តីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ** សម្រេចបាននូវសមិទ្ធផលសំខាន់ៗមានដូចជា (១) របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃមុខងារអប់រំ និងការដាក់ចេញអនុក្រឹត្យលេខ២១៣អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស (២) ការចុះគាំទ្រ ពង្រឹងការអនុវត្តមុខងារ និងការគ្រប់គ្រងគម្រោង មូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយណែនាំអនុវត្តនូវគោលការណ៍ និងនីតិវិធីនៃការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (៣) ការងារគណនេយ្យភាពសង្គមត្រូវបានអនុវត្តនៅរដ្ឋបាលក្រុង ស្រុកគោលដៅចំនួន៣៧ដោយផ្តោតលើការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ និងអនុវត្តនៅថ្នាក់ឃុំ សង្កាត់សរុបចំនួន១.៥៤៥ ឃុំ សង្កាត់ក្នុង២៥រាជធានី ខេត្ត ដោយផ្តោតលើសេវាសំខាន់ៗចំនួន៣ គឺ ការផ្តល់សេវារដ្ឋបាលរបស់ឃុំ សង្កាត់ សេវាអប់រំបឋមសិក្សា និងសេវាមណ្ឌលសុខភាព (៤) ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមានចំនួន២៥ និងការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន១៩០ ត្រូវបានបង្កើត និងបានដាក់ឱ្យដំណើរការ។ ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្តបានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋសរុបចំនួន១.៤២៩ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៦៣៨ករណី (បញ្ចប់ការដោះស្រាយចំនួន៥៨៤ករណី ស្មើនឹង៩១% កំពុងដោះស្រាយចំនួន៥៤ករណី)។ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក

ខណ្ឌ បានទទួលបណ្តឹង និងព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋបានចំនួនសរុប១៣.៦៩០ករណី ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចមានចំនួន៣០៣ករណី (បញ្ចប់ការដោះស្រាយ២៧៧ករណី ស្មើនឹង៩១% កំពុងដំណើរការ ២៦ករណី)។

**សមាសភាគទី៣ ៖ ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** សម្រេចបាននូវសមិទ្ធផលសំខាន់ៗមានដូចជា (១) អនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងឯកសារពិពណ៌នាមុខតំណែង (មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈ) សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ក្នុងនោះមុខតំណែងសម្រាប់រដ្ឋបាលស្រុកចំនួន៥៤ រដ្ឋបាលក្រុងចំនួន៥២ និងរដ្ឋបាលខណ្ឌចំនួន៥៤ (២) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ទិន្នន័យបុគ្គលិក ការជ្រើសរើស ការត្រួតពិនិត្យវាយតម្លៃ ការបំពេញការងារសម្រាប់ដំឡើងថ្នាក់ ឋានន្តរសក្តិ ការតែងតាំងមុខតំណែង ការដាក់ពិន័យ ការចូលនិវត្តន៍ និងការគ្រប់គ្រងផ្សេងៗទៀតត្រូវបាននិងកំពុងសិក្សា និងរៀបចំ (៣) សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងដំណើរការពិនិត្យ និងកែសម្រួល (៤) បានរៀបចំវគ្គបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣៧វគ្គ មានសិក្ខាកាមសរុបចំនួន១.៥៧០នាក់ ស្ត្រីចំនួន៥៨៤នាក់ ដោយផ្តោតលើប្រធានបទសំខាន់ៗមានដូចជា៖ នវានុវត្តន៍សម្រាប់រដ្ឋបាលមូលដ្ឋាន អន្តរាគមន៍អភិវឌ្ឍសមត្ថភាព តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តួនាទី ភារកិច្ចស្មៀនដល់រដ្ឋបាលឃុំ សង្កាត់ សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ ស្ត្រី និងការដឹកនាំ ការប្រែប្រួលអាកាសធាតុ ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ លក្ខខណ្ឌការងារ ថវិកាឆ្លើយតបនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ (៥) រដ្ឋបាលរាជធានី ខេត្តបានសម្របសម្រួល និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន៧៥វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ១.៨០០រូប ដោយផ្តោតលើប្រធានបទសំខាន់ៗមានដូចជា៖ ការងារគណនេយ្យភាពសង្គម ការកសាងផែនការ និងការរៀបចំថវិកា អន្តរាគមន៍អភិវឌ្ឍសមត្ថភាព តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តួនាទី ភារកិច្ចស្មៀនដល់រដ្ឋបាលឃុំ សង្កាត់ ការតាក់តែងលិខិតរដ្ឋបាល និងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាឆ្លើយតបនឹងយេនឌ័រក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ (៦) ការពង្រឹងសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋានតាមរយៈការអភិវឌ្ឍសមត្ថភាពមន្ត្រីសាលា ការពង្រឹង និងពង្រីកភាពជាដៃគូជាមួយស្ថាប័នអភិវឌ្ឍសមត្ថភាពទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ព្រមទាំងបានដំណើរការសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រោមកម្ចីសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

**សមាសភាគទី៤៖ ស្តីពីវិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** សម្រេចបាននូវសមិទ្ធផលសំខាន់ៗមានដូចជា (១) រដ្ឋបាលរាជធានី ខេត្តទាំងអស់បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា (២០២៤-២០២៦) និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤របស់ខ្លួន ផ្អែកតាមបញ្ជីគម្រោងជាអាទិភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ស្របតាមលិខិតបទដ្ឋានណែនាំជាធរមាន (២) អនុក្រឹត្យលេខ១៥២ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុកពីឆ្នាំ២០២៤-២០២៨ អនុក្រឹត្យលេខ១៥៣ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋ

ជូនមូលនិធិឃុំ សង្កាត់ពីឆ្នាំ២០២៤-២០២៨ និងអនុក្រឹត្យលេខ១៥៤ អនក្រ.បក ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនមូលនិធិរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ពីឆ្នាំ២០២៤-២០២៨ ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ (៣) ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន **៣.៦៦១.៧១១**លានរៀលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០២៣ ក្នុងនោះរដ្ឋបាលរាជធានី ខេត្តចំនួន**២.៥៧៦.០០២លានរៀល** រដ្ឋបាលក្រុង ស្រុកចំនួន**៣៣២.៣៦០លានរៀល** និងរដ្ឋបាលឃុំ សង្កាត់ចំនួន**៧៥៣.៣៤៩លានរៀល** (៤) មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យអប់រំប្រមាណជាង៣៨លានដុល្លារត្រូវបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤នៃខេត្តបាត់ដំបង។ មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារក្នុងវិស័យសុខាភិបាលប្រមាណ២១២លានដុល្លារ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តទាំង២៥ មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រមាណ២លានដុល្លារត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុងទាំង២៨ និងធនធានថវិកាចំនួនប្រមាណ ៣៨លានដុល្លារសម្រាប់គាំទ្រការិយាល័យជំនាញទាំង២០ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ (៥) មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ចំនួន២៧.៦២៩លានរៀល ត្រូវបានផ្ទេរសម្រាប់គាំទ្រគម្រោងក្រុង ស្រុកគោលដៅ (៦) រដ្ឋបាលរាជធានី ខេត្តបានចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរបស់ខ្លួនទៅឱ្យរដ្ឋបាលក្រុង ស្រុកចំនួន៤% និងទៅឱ្យរដ្ឋបាលឃុំ សង្កាត់ចំនួន៥% (៧) អនុក្រឹត្យលេខ ២៨៣អនក្រ.បក ស្តីពីគោលការណ៍ និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងក្របខ័ណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ (៨) ទិន្នន័យស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) និងបានធ្វើបច្ចុប្បន្នភាពបញ្ចូលព័ត៌មានអាកាសធាតុ និងទាញយករបាយការណ៍ក្នុងប្រព័ន្ធ SPD និង PID និងបានធ្វើតេស្តសាកល្បងនៅខេត្តកំពត ខេត្តព្រៃវែង និងខេត្តស្វាយរៀង (៩) រដ្ឋបាលរាជធានី ខេត្តទាំងអស់កំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**សមាសភាគទី៥៖ ស្តីពីការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** សម្រេចបាននូវសមិទ្ធផលសំខាន់ៗមានដូចជា (១) សេចក្តីណែនាំបច្ចេកទេសសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួងសាមីនីមួយៗ (២) បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានពិនិត្យ និងកែសម្រួល (៣) គម្រោងសាកល្បងពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុកក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងភាពជាដៃគូជាមួយវិស័យឯកជន ត្រូវបានរៀបចំនិងអនុវត្តសាកល្បងនៅឃុំបាសាក់ ស្រុករុក្ខគិរី ខេត្តបាត់ដំបង (៤) រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់បានរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួនសរុបប្រមាណជាង២.០០០គម្រោងក្នុងឆ្នាំ២០២៣នេះ (៥) គម្រោង/កម្មវិធីដាច់ដោយឡែកចំនួន១៣គម្រោង/កម្មវិធី ដែលគាំទ្រហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងការបង្កើនជីវភាព

រស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមស្ត្រី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូច ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សេវាសង្គម គណនេយ្យភាពសង្គម និងការបែងចែកដីសម្បទានសង្គមកិច្ច (៦) អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន៦២៥.៧២៩សេវា ថយចុះ១០% ធៀបនឹងចំនួនសេវាដែលបានផ្តល់ក្នុងឆ្នាំ២០២២ និងទទួលបានចំណូលសរុបចំនួន ៩០.៨៩៦.៩៣០.៥៤៩រៀល (២២.៤៤៣.៦៨៦ដុល្លារអាមេរិក) ថយចុះ២០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ២.៦៦២.៥៩៨សេវា កើនឡើង៧០% ធៀបនឹងសេវាសរុបដែលផ្តល់ក្នុងឆ្នាំ២០២២ និងទទួលបានចំណូលពីការផ្តល់សេវារដ្ឋបាលសរុបចំនួន១៣.៣១៧.៤២០.០៥៦រៀល (៣.២៨៨.២៥១ដុល្លារអាមេរិក) កើនឡើង ២០% ធៀបនឹងចំណូលសរុបឆ្នាំ២០២២។ ជាមួយគ្នានេះ អង្គភាពច្រកចេញចូលតែមួយបាននិងកំពុងដំណើរការសាកល្បងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញក្នុងវិស័យចំនួន៤រួមមាន៖ វិស័យវប្បធម៌ ឧស្សាហកម្ម ទេសចរណ៍ កសិកម្ម និង (៧) បានសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយសុវត្ថិភាព បរិស្ថាន និងសង្គមក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០២៣ ក្នុងគោលបំណងពិនិត្យ និងបញ្ជ្រាបគោលនយោបាយនេះក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

ជាមួយនឹងសមិទ្ធផលដែលបានរៀបរាប់ខាងលើ ការអនុវត្ត ផ.ស.ថ. ឆ្នាំ ២០២៣ បានជួបប្រទះនូវបញ្ហាប្រឈមជាចម្បងមួយចំនួនមានដូចជា ៖

- ក្រសួង ស្ថាប័នអនុវត្តមួយចំនួន ពុំមានថវិកាសមស្របសម្រាប់អនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នរបស់ខ្លួន ជាពិសេសក្រសួងពាក់ព័ន្ធនឹងការផ្ទេរមុខងារ
- ថវិកាសម្រាប់អនុវត្តមុខងារចំនួន៥៥ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងវិស័យចំនួន១៩ នៅពុំទាន់បានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ( កន្លងមកមានការផ្ទេរថវិកាសម្រាប់តែប្រាក់ខែបុគ្គលិក និងប្រាក់សម្រាប់គាំទ្រផ្នែករដ្ឋបាល)
- សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារមួយចំនួនដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំបានរៀបចំបញ្ចប់ និងពុំទាន់បានបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពន្យារពេល និងការផ្អាកអនុវត្តសកម្មភាពមួយចំនួនដែលមានកមណត់ក្នុងសេចក្តីសម្រេចរួមឆ្នាំ២០២៣ ដោយឆ្នាំ២០២៣នេះ ជាឆ្នាំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧
- កង្វះបុគ្គលិកមានសមត្ថភាព និងជំនាញ និងកង្វះការទទួលខុសត្រូវជាក់លាក់របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដែលជាបញ្ហាសំខាន់ត្រូវយកចិត្តទុកដាក់ក្នុងរៀបចំមន្ត្រីឱ្យបានសមស្របតាមជំនាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាពជំនាញ រៀបចំឱ្យមានលក្ខខណ្ឌការងារច្បាស់លាស់ និងផ្តល់ការលើកទឹកចិត្ត
- ភាពមានកម្រិតក្នុងការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងារពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

### គ. ដំណើរការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដោយផ្អែកលើសកម្មភាពលម្អិតនៃសកម្មភាពជាអាទិភាពរបស់ផអ៥ទី១ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៣ ដែលត្រូវបន្តអនុវត្តក្នុងឆ្នាំ២០២៤ និងតាមរយៈដំណើរការដែលមានការចូលរួម និងការប្រឹក្សាយោបល់ជាមួយស្ថាប័នអនុវត្តនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានាដែលបានអនុវត្តចាប់ពីខែឧសភា ដល់ខែធ្នូ ឆ្នាំ២០២៣។ កិច្ចការសំខាន់ៗដែលបានអនុវត្តក្នុងដំណើរការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤ រួមមាន៖

- លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំសេចក្តីព្រាងបឋមនូវសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសកម្មភាពជាក់លាក់តាមក្រសួង ស្ថាប័ននីមួយៗ
- ស្ថាប័នអនុវត្ត និងគម្រោង/កម្មវិធីនានាពិនិត្យ និងរៀបចំសេចក្តីព្រាងសកម្មភាពលម្អិតនៃ ផ.ស.ថ.ឆ្នាំ២០២៤របស់ខ្លួន ដើម្បីដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប. ពិនិត្យបូកសរុប និងផ្តល់យោបល់
- កិច្ចប្រជុំណែនាំ និងពិគ្រោះយោបល់ជាមួយស្ថាប័នអនុវត្ត និងគម្រោង កម្មវិធីនានាអំពីសេចក្តីព្រាងបឋមនៃសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ និងការរៀបចំ ផ.ស.ថ. ឆ្នាំ២០២៤
- រៀបចំសេចក្តីព្រាងឯកសារ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. និងបានបញ្ជូនទៅដៃគូ និងអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់យោបល់
- ដាក់សេចក្តីព្រាងចុងក្រោយនៃ ផ.ស.ថ. ឆ្នាំ២០២៤ ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត។

### ឃ. រចនាសម្ព័ន្ធនៃ ផ.ស.ថ. ឆ្នាំ២០២៤

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. (ផ.ស.ថ.) រៀបរាប់អំពីសកម្មភាពលម្អិតនានាក្នុងឆ្នាំ២០២៤ ដែលត្រូវអនុវត្ត និងសម្រេចដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងភាគីពាក់ព័ន្ធនានា។ ផែនការនេះរួមមាន**សកម្មភាពជាអាទិភាពសរុបចំនួន៨៧ សកម្មភាពលម្អិតសរុបចំនួន៣១៧ និងសូចនាករសរុបចំនួន១៣៩** និងថវិកាប៉ាន់ស្មានសរុបចំនួន**៧.២៣០.២៨១លានរៀល ស្មើនឹង ១.៨០៧,៥៧លានដុល្លារអាមេរិកអាមេរិក** ដែលក្នុងនោះមានថវិកាគាំទ្រទៅលើសកម្មភាពស្នូលនៃកំណែទម្រង់មានចំនួន**១១៩.០៧៣លានរៀល ស្មើនឹង៣០លានដុល្លារអាមេរិក។**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ បែងចែកជា៤ជំពូក និងរួមមានឧបសម្ព័ន្ធចំនួន៣។

**ជំពូកទី១ ៖** រៀបរាប់អំពីទិដ្ឋភាពទូទៅនៃ ផ.ស.ថ. ដែលរួមមានសេចក្តីផ្តើម សមិទ្ធផល និងបញ្ហាប្រឈមដំណើរការរៀបចំ ផ.ស.ថ. និងរចនាសម្ព័ន្ធ ផ.ស.ថ.។

**ជំពូកទី២ ៖** គឺជាផ្នែកមួយដ៏សំខាន់នៃឯកសារ ផ.ស.ថ. ឆ្នាំ២០២៤។ ជំពូកនេះបែងចែកជា៥សមាសភាគ និងរួមបញ្ចូលនូវលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពដែលត្រូវសម្រេចក្នុងឆ្នាំ២០២៤

ដែលបានរៀបចំឡើងផ្អែកលើសកម្មភាពជាអាទិភាពនៃផអ៥ទី១ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និង សកម្មភាពលម្អិតនៃផ.ស.ថ.ឆ្នាំ២០២៣ដែលត្រូវបន្តអនុវត្តក្នុងឆ្នាំ២០២៤។ សមាសភាគទាំង៥ រួមមាន ដូចខាងក្រោម៖

១. ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

២. រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

៤. វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ

៥. ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ជារួម ក្នុងសមាសភាគនីមួយៗ មានបរិយាយអំពីសមិទ្ធផលរំពឹងទុក លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាពដែលត្រូវសម្រេចរួមបញ្ចូលទាំងសូចនាករ និងចំណុចដៅ ស្ថាប័នទទួលខុសត្រូវអនុវត្ត និងថវិកាគ្រោងសម្រាប់ឆ្នាំ២០២៤។

ព័ត៌មានលម្អិតអំពីសកម្មភាពដែលត្រូវអនុវត្ត រួមបញ្ចូលទាំងស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្ត ថវិកា និងក្របខ័ណ្ឌពេលវេលាអនុវត្តមានរៀបរាប់នៅក្នុងតារាងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. នៃឧបសម្ព័ន្ធទី២។

**ជំពូកទី៣ ៖** អំពីថវិកា ផ.ស.ថ. ឆ្នាំ២០២៤ បង្ហាញពីផែនការចំណាយរួម ធនធានថវិកាដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០២៤ ថវិកាចំណាយសម្រាប់គាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់ និងប្រភពផ្តល់មូលនិធិ។

**ជំពូកទី៤ ៖** អំពីការគ្រប់គ្រង ផ.ស.ថ. ឆ្នាំ២០២៤ រៀបរាប់អំពីបែបផែនសម្រាប់ការគ្រប់គ្រង និងការអនុវត្តសកម្មភាព ការអនុវត្តថវិកា និងការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្ត ផ.ស.ថ.។

ឯកសារ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលឧបសម្ព័ន្ធចំនួន០៣ រួមមានដូចខាងក្រោម៖

ឧបសម្ព័ន្ធទី១ ៖ តារាងក្របខ័ណ្ឌលទ្ធផលនៃ ផ.ស.ថ. ឆ្នាំ២០២៤

ឧបសម្ព័ន្ធទី២ ៖ តារាងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤

ឧបសម្ព័ន្ធទី៣ ៖ តារាងគ្រប់គ្រងហានិភ័យ

# II. សមាសភាគនៃ ផ.ស.ថ. ឆ្នាំ២០២៤

## សមាសភាគទីមួយ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

### ក. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទីមួយគឺ យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

### ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើ សមាសភាគទីមួយបានកំណត់នូវលទ្ធផលរំពឹងទុកសរុបចំនួន០៥ និងសកម្មភាពជាអាទិភាពចំនួន២១ សកម្មភាពលម្អិតចំនួន៩១ រួមបញ្ចូលសូចនាករចំនួន៣៥ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងមានថវិកាសរុបចំនួន១២.៩៦១លានរៀល ស្មើនឹង៣,២៤លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពទាំងនេះ មានរៀបរាប់ដូចខាងក្រោម ៖

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.1 | **យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន** | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់<br>សកម្មភាពនេះផ្តោតលើការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. ឱ្យបានទៀងទាត់ និងរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផអ៥ទី១។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព<br>សកម្មភាពនេះផ្តោតទៅលើការពិនិត្យ និងកែសម្រួលអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. ការរៀបចំអង្គភាព ដើម្បីជួយដល់អនុគណៈកម្មាធិការនីមួយៗក្នុងការរៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំការអនុវត្តគោលនយោបាយនានា។ | គ.ជ.អ.ប. និងស្ថាប័នជាប្រធានអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប. |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.1.3 | **ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំនិងដាក់ឱ្យដំណើរការនូវយន្តការចាំបាច់នានារបស់ គ.ជ.អ.ប. (ដូចជា ក្រុមការងារក្រុមសីលធម៌ និងសវនកម្ម) ការពិនិត្យមើលឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. ព្រមទាំងកិច្ចប្រជុំក្រុមការងារដឹកនាំ និងត្រួតពិនិត្យលើការរៀបចំ ការអនុវត្តគម្រោង និងកម្មវិធីផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.1.4 | **ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (គ.ដ.វ.វ.)**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំបង្កើត ឬកែសម្រួល (គ.ដ.វ.វ.) និងរៀបចំកិច្ចប្រជុំ (គ.ដ.វ.វ.) របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍសមត្ថភាព សិក្ខាសាលាឆ្លុះបញ្ចាំង និងរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមរបស់រាជធានី ខេត្ត ក្រុង ស្រុក ដាក់ជូន គ.ជ.អ.ប.។ | ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 1.1.5 | **ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃកំណែទម្រង់ពាបូក១ និងរៀបចំ និងអនុវត្តផែនការសកម្មភាពរួមប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់ពាបូក១។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>អគ្គលេខាធិការដ្ឋាន PFM<br>អគ្គលេខាធិការដ្ឋាន PAR<br>អគ្គលេខាធិការដ្ឋាននៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| 1.1.6 | **ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតទៅលើ (១) ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រោមម្លប់សន្តិភាព និងការអភិវឌ្ឍ ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និង (២) ការបន្តសិក្សា និងរៀបចំគោលការណ៍ណែនាំអំពីរបៀបនៃការរៀបចំកិច្ចប្រជុំ ឬវេទិការវាងក្រុមប្រឹក្សានិងអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការរៀបចំកិច្ចប្រជុំ ឬវេទិការវាងក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.1.7 | **ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានាប្រកបដោយភាពស្ថាបនា**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីចែករំលែកព័ត៌មានគ្នាទៅវិញទៅមក និងការប្រមូលធាតុចូលពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.1.8 | **ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា និងរៀបចំគោលការណ៍ណែនាំអំពីរបៀបនៃការរៀបចំកិច្ចប្រជុំ ឬវេទិការវាងក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងពង្រឹងតួនាទី និងភារកិច្ចរបស់ក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័នសម្រាប់គាំទ្រដល់ការអនុវត្តការងារកំណែទម្រង់នានា ផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពអំពីគោលនយោបាយសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ដល់មន្ត្រីពាក់ព័ន្ធការងារយេនឌ័រដោយក្រសួង ស្ថាប័ន ពង្រឹងតួនាទី និងភារកិច្ចរបស់ គ.ក.ស.ក. សម្រាប់គាំទ្រដល់ការអនុវត្តកជទី២របស់រាជធានី ខេត្ត។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>ក្រសួងកិច្ចការនារី<br>ក្រសួង ស្ថាប័ន និង<br>រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| 1.2 | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | |
| 1.2.1 | **ការកែលម្អ និងការពង្រឹងយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទង**<br>សកម្មភាពនេះផ្តោតទៅលើការពិនិត្យ និងកែសម្រួលយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទងសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទងក្នុងការលើកកម្ពស់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.2.2 | **ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទង (យុទ្ធសាស្រ្តដែលមានស្រាប់)**<br>សកម្មភាពនេះផ្តោតទៅលើការផលិតឧបករណ៍ព័ត៌មានទាក់ទងនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា និងអភិវឌ្ឍសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីការរៀបចំការផលិតឯកសារព័ត៌មាន និងចុះប្រមូលព័ត៌មាននានា។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>ក្រសួង ស្ថាប័ន និង<br>រាជធានី ខេត្ត |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.2.3 | **ការវាស់វែងលទ្ធផលនៃការប្រាស្រ័យទាក់ទង**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំវិធីសាស្ត្រ និងឧបករណ៍នៃការអង្កេតដើមគ្រាស្តីពីការអនុវត្តយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងសម្រាប់ផអ៥ទី១ និងរៀបចំការអង្កេតដើមគ្រាស្តីពីការអនុវត្តយុទ្ធសាស្ត្រនៃការប្រាស្រ័យទាក់ទងសម្រាប់ផអ៥ទី១។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.3 | **កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | |
| 1.3.1 | **ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការអនុវត្តដំណាក់កាលនីមួយៗនៃកជទី២**<br>សកម្មភាពនេះផ្តោតលើការកិច្ចប្រជុំ និងសិក្ខាសាលាផ្សព្វផ្សាយស្តីពីផអ៥ទី១នៃកជទី២ និងការរៀបចំយុទ្ធសាស្ត្រ និងបញ្ជីគម្រោងអាទិភាពរយៈពេលមធ្យមពាក់ព័ន្ធនឹងការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.3.2 | **ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាពអំពីបែបបទនីតិវិធីការអនុវគម្រោងនានា និងការគាំទ្រកិច្ចប្រតិបត្តិការនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 1.3.3 | **ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំកិច្ចប្រជុំណែនាំស្តីពីការដាក់បញ្ចូលសកម្មភាពអាទិភាពស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |
| 1.3.4 | **ការរៀបចំគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍ ឬអង្គការសង្គមស៊ីវិលនានាដោយបន្ស៊ីជាមួយកជទី២**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា និងកែសម្រួលយុទ្ធសាស្ត្រស្តីពីការសម្របសម្រួល និងការធ្វើសុខដុមនីយកម្មនៃគម្រោងកម្មវិធីនានារបស់ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលជាមួយកជទី២ និងការរៀបចំសេចក្តីណែនាំស្តីពីការបន្ស៊ីសកម្មភាពនៃគម្រោងនានាដែលគាំទ្រថវិកាពីដៃគូអភិវឌ្ឍ ឬអង្គការសង្គមស៊ីវិលនានាជាមួយផអ៥ទី១។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.3.5 | **ការរៀបចំ និងការអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមថ្មីៗ**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា និងរៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.3.6 | **ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២**<br>សកម្មភាពនេះផ្តោតទៅលើការពង្រឹងការអនុវត្តសវនកម្មផ្ទៃក្នុងជាទៀងទាត់លើការអនុវត្តគម្រោង កម្មវិធីនានាក្រោមការសម្របសម្រួល និងដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងការរៀបចំការអង្កេតស្តីពីអភិបាលកិច្ច និងការធ្វើសវនកម្មយេនឌ័រការរៀបចំការវាយតម្លៃលទ្ធផលនៃការរៀបចំការវាយតម្លៃលទ្ធផលនៃការអនុវត្តកជទី១ ត្រួតពិនិត្យ និងគាំទ្រការអនុវត្ត ផ.ស.ថ. ប្រចាំឆ្នាំដោយក្រសួង ស្ថាប័ន ការរៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុងរបស់ គ.ជ.អ.ប. សម្របសម្រួល និងអនុវត្តសវនកម្មផ្ទៃក្រៅនៃថវិការបស់គម្រោងដៃគូនានា និងការរៀបចំការវាយតម្លៃអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយ ឬលិខិតបទដ្ឋាន និងរៀបចំកិច្ចប្រជុំការងារសវនកម្មផ្ទៃក្នុង និងក្រុមសីលធម៌។ | លេខាធិការដ្ឋាន គ.ជ.អ.ប.<br>រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **1.4** | **រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | |
| 1.4.3 | **រចនាសម្ព័ន្ធ និងប្រព័ន្ធនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបានកែសម្រួល ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា និងវិភាគតួនាទីរបស់ក្រសួង ស្ថាប័ន ដើម្បីពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នក្នុងការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា។ | ក្រសួង ស្ថាប័ន |
| **1.5** | **ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់** | |
| 1.5.1 | **ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតទៅលើការរៀបចំកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ | សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 1.5.2 | **ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី របស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា វាយតម្លៃ និងកំណត់អំពីជម្រើសសមស្របនានាសម្រាប់កែសម្រួលរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ | សមាគមជាតិក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ |
| 1.5.4 | **ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់**<br>សកម្មភាពនេះផ្តោតទៅលើការសិក្សា និងរៀបចំយុទ្ធសាស្ត្រស្តីពីការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការកំណែទម្រង់ និងការរៀបចំកិច្ចប្រជុំរវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

*** <u>**កំណត់សម្គាល់៖**</u> សកម្មភាពជាអាទិភាពពាខ្ទង់ដែលមិនបានរៀបចំតាមលំដាប់លេខរៀងដោយសារសកម្មភាពអាទិភាពមួយចំនួននៃផអ៥ទី១ មិនត្រូវបានយកមកអនុវត្ត ឬបានអនុវត្តចប់រួចហើយ។

តារាងផែនការសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលសមាសភាគ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សកម្មភាពលម្អិត ថវិកា ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវអនុវត្តដែលពាក់ព័ន្ធនឹងសមាសភាគទីមួយនេះ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី២។

### តារាងទី១ ៖ ថវិកាតាមលទ្ធផលរំពឹងទុកនីមួយៗ (គិតជាលានរៀល)

| កូដ | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 1.1 | យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការរីកចម្រើនទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | 3,086 |
| 1.2 | ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | 429 |
| 1.3 | កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | 7,976 |
| 1.4 | រចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ជាតិសម្រាប់ធានាការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | 7 |
| 1.5 | ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់ | 1,463 |
| | **សរុបរួម** | 12,961 |

# តារាងទី២៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីមួយ

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 1 | **ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖**<br>**យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំតាក់តែង និងអនុវត្តន៍កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | |
| 1.1 | **យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន** | | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | 2 | 1 | 1 |
| | | 2. ចំនួនសរុបលិខិតបទដ្ឋាន/ឯកសារដែលបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. | ឯកសារ | 3 | 4 | 2 | 2 |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព | 3. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | | 6 | 3 | 3 |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 4. រចនាសម្ព័ន្ធនៃអង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល | រចនាសម្ព័ន្ធ | សេចក្តីព្រាង | អនុម័ត | 1 | |
| | | 5. ចំនួនសរុបវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់បុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. | វគ្គ | 4 | 4 | 2 | 2 |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 6. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 40 | 48 | 24 | 24 |
| | | 7. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត | កិច្ចប្រជុំ | 50 | 50 | 25 | 25 |
| | | 8. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក | កិច្ចប្រជុំ | 388 | 388 | 194 | 194 |
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 9. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |
| | | 10. ផែនការសកម្មភាពរួមប្រចាំឆមាសដែលបានរៀបចំ | ផែនការ | 2 | 2 | 1 | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 1.1.6 | ការរៀបចំវេទិកាវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា | 11. ការសិក្សាអំពីការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សិក្សា | | 1 | | 1 |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានាប្រកបដោយភាពស្ថាបនា | 12. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 1 | 2 | 1 | 1 |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 13. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់រាជធានី ខេត្ត ដែលបានរៀបចំ | កិច្ចប្រជុំ | 300 | 300 | 150 | 150 |
| | | 14. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់ក្រុង ស្រុក ខណ្ឌ ដែលបានរៀបចំ | កិច្ចប្រជុំ | 2,496 | 2,496 | 1,248 | 1,248 |
| **1.2** | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | | | | | | |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 15. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ត្រូវបានពិនិត្យកែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | | 1 | 1 | |
| 1.2.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 16. ចំនួនសរុបវេទិកា ឬកម្មវិធីផ្សព្វផ្សាយអំពីចក្ខុវិស័យ គោលដៅ និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ | វេទិកា | 12 | 12 | 6 | 6 |
| | | 17. ចំនួនសរុបឯកសារព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 5 | 5 | 2 | 3 |
| **1.3** | **កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | | | | | | |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 18. ផ.ស.ថ. ឆ្នាំ២០២៤ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ. | 1 | 1 | 1 | |
| | | 19. ភាគរយសរុបសកម្មភាពអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២៤ ដែលសម្រេចបាន | ភាគរយ | 80% | 80% | 40% | 40% |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 20. សេចក្ដីព្រាង ផ.ស.ថ. ឆ្នាំ២០២៥ ត្រូវបានរៀបចំ | ផ.ស.ថ. | | 1 | | 1 |
| | | 21. ចំនួនសរុបនៃសេចក្ដីសម្រេចរួមដែលបានរៀបចំ និងអនុម័ត | សេចក្ដីសម្រេចរួម | 45 | 46 | 46 | |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 22. ចំនួនក្រសួង ស្ថាប័នបានបញ្ចូលសកម្មភាពនៃ ផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 21 | 21 | 21 | |
| | | 23. ចំនួនរដ្ឋបាលរាជធានី ខេត្តបានបញ្ចូលសកម្មភាព នៃផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 25 | 25 | 25 | |
| 1.3.6 | ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ | 24. ការអង្កេតអភិបាលកិច្ច | ការអង្កេត | | 1 | | 1 |
| | | 25. ការវាយតម្លៃលើការអនុវត្តកជទី១ | ការវាយតម្លៃ | | 1 | | 1 |
| | | 26. របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផ.ស.ថ. របស់ គ.ជ.អ.ប. | របាយការណ៍ | 2 | 1 | 1 | 1 |
| | | 27. សវនកម្មយេនឌ័រ | ការអង្កេត | | 1 | | 1 |
| **1.5** | **ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់** | | | | | | |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 28. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |
| | | 29. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |
| | | 30. ផែនការយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ផែនការ | | 1 | | 1 |
| | | 31. ចំនួនសរុបនៃវគ្គបណ្ដុះបណ្ដាលដែលបានរៀបចំ សម្រាប់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | វគ្គ | 3 | 4 | 2 | 2 |
| | | 32. ចំនួនសរុបនៃវគ្គបណ្ដុះបណ្ដាលដែលបានរៀបចំ សម្រាប់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | វគ្គ | 3 | 4 | 2 | 2 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 1.5.2 | ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 33. ការសិក្សាអំពីជម្រើសនានាត្រូវបានអនុវត្ត | ការសិក្សា | | 1 | | 1 |
| 1.5.4 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | 34. ការសិក្សា និងរៀបចំយុទ្ធសាស្ត្រនៃការចូលរួមរបស់អង្គការសង្គមស៊ីវិល | ការសិក្សា | | 1 | | 1 |
| | | 35. ចំនួនកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលលើការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់ | កិច្ចប្រជុំ | 2 | 2 | 1 | 1 |

# សមាសភាគទីពីរ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ក. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទីពីរគឺ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។

## ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើ សមាសភាគទីពីរបានកំណត់នូវលទ្ធផលរំពឹងទុកសរុបចំនួន០៨ សកម្មភាពជាអាទិភាពចំនួន១៩ និងសកម្មភាពលម្អិតចំនួន៩៥ រួមបញ្ចូលសូចនាករចំនួន៣៥ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងមានថវិកាសរុបចំនួន៣៥.៩៩១លានរៀល ស្មើនឹង៨,៨៧លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពទាំងនេះ មានរៀបរាប់ដូចខាងក្រោម៖

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 2.1 | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ** | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក<br>សកម្មភាពនេះផ្តោតជាសំខាន់លើការចុះគាំទ្រ តាមដាន វាយតម្លៃលើការអនុវត្តមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ផ្សព្វផ្សាយ និងការបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី និងបែបបទនៃការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំប្រមូល និងចងក្រងទិន្នន័យដើមគ្រានៃការអនុវត្តមុខងារក្នុងវិស័យអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សិក្សាអំពីលទ្ធភាពនៃការផ្ទេរមុខងារសុខាភិបាលមួយចំនួនពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសិក្សាពីលទ្ធភាពក្នុងការបង្កើតការិយាល័យសុខាភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរៀបចំគោលការណ៍ណែនាំស្តីពីការពង្រឹងការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្នុងកិច្ចសហការរួមគ្នានៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ | ក្រសួង ស្ថាប័ន ក្រសួងមហាផ្ទៃ ក្រសួងអប់រំ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរាជធានី ខេត្ត |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 2.1.2 | **ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់**<br>សកម្មភាពនេះផ្ដោតជាសំខាន់លើការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងាររបស់ឃុំ សង្កាត់ និងត្រួតពិនិត្យ និងផ្ដល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោង។ | ក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 2.1.3 | **ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន**<br>សកម្មភាពនេះផ្ដោតជាសំខាន់លើការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន និងសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន។ | ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 2.1.4 | **ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ**<br>សកម្មភាពនេះផ្ដោតជាសំខាន់លើការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ។ | ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 2.2 | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | |
| 2.2.1 | **ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត**<br>សកម្មភាពនេះផ្ដោតជាសំខាន់លើការសិក្សា និងវាយតម្លៃលើរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តនៅក្នុងប្រទេស សិក្សាឈ្វេងយល់ ដកស្រង់បទពិសោធ និងសិក្ខាសាលាផ្លាស់ប្ដូរលើការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តនៅបណ្ដាប្រទេសមួយចំនួន និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នក្នុងការកំណត់នូវជម្រើសសម្រាប់កែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 2.3 | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | |
| 2.3.1 | **ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលរាជធានី**<br>សកម្មភាពនេះផ្ដោតជាសំខាន់លើការសិក្សា និងវាយតម្លៃលើស្ថានភាពបច្ចុប្បន្ននៃរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានីភ្នំពេញ និងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នក្នុងការក្នុងការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលរាជធានី។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 2.4 | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត** | |
| 2.4.2 | **ការការពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសៗគ្នា**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសៗគ្នាតាមរយៈការផ្សព្វផ្សាយ ការណែនាំ និងការបណ្តុះបណ្តាល។ | ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 2.4.3 | **ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ**<br>សកម្មភាពនេះផ្តោតសំខាន់លើការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំបណ្តុះបណ្តាលអំពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមហាផ្ទៃ |
| 2.4.4 | **ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងការរៀបចំវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋដោយរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ការចុះជួបពិភាក្សា និងប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយព័ត៌មាននានាពីការបំពេញការងារ និងការផ្តល់សេវា ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋក្នុងការរៀបចំ និងអនុម័តលើគោលនយោបាយ ផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការលើកកម្ពស់ ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន ការរៀបចំឱ្យមានយន្តការនៃការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌ និងការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីទំនាក់ទំនងការងារ និងគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 2.5 | **សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | |
| 2.5.1 | **ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សាអំពីការកែសម្រួលមុខងារ និងរចនាសម្ព័ន្ធនានានៃគណៈកម្មាធិការរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និង រដ្ឋបាលថ្នាក់ក្រោមជាតិ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 2.5.2 | **ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សាអំពីលទ្ធភាពនៃការរៀបចំឱ្យមានលេខាធិការដ្ឋានសម្រាប់ក្រុមប្រឹក្សារដ្ឋបាលរាជធានី ខេត្ត។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងរាជធានី ខេត្ត |
| 2.5.3 | **ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សាអំពីលទ្ធភាព និងរៀបចំឱ្យមានកញ្ចប់ថវិកាគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 2.6 | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាបាននូវជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | |
| 2.6.1 | **ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សាអំពីជម្រើសនៃការរៀបចំឱ្យមានអង្គភាព និង/ឬយន្តការជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗសម្រាប់ការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ពង្រីកការសាកល្បងការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌអភិវឌ្ឍសមត្ថភាពអំពីការងារគណនេយ្យភាពសង្គមដល់អង្គភាពផ្តល់សេវា និងអ្នកពាក់ព័ន្ធនានាដោយក្រុង ស្រុក ខណ្ឌ ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីការងារគណនេយ្យភាពសង្គមដោយក្រុង ស្រុក ខណ្ឌ ការរៀបចំ ផលិត និងបិតផ្សព្វផ្សាយទិន្នន័យលទ្ធផលការងារ (Post-On) ដោយក្រុង ស្រុក ខណ្ឌ និងការរៀបចំ និងដាក់ឱ្យអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលបន្ទាប់ (២០២៦-២០៣០)។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ |
| 2.6.2 | **ការពង្រឹងយន្តការសម្រាប់ទទួល និងដោះស្រាយបណ្តឹងតវ៉ា និងសំណើសំណូមពររបស់ប្រជាពលរដ្ឋ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាព ត្រួតពិនិត្យ និងវាយតម្លៃការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនានាដោយការិយាល័យប្រជាពលរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ | ក្រសួងមហាផ្ទៃ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 2.6.3 | **ការលើកកម្ពស់ការចូលរួមរបស់អង្គការស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីថវិកា ផែនការ គម្រោង/កម្មវិធី និងសេវាសាធារណៈ ការរៀបចំកិច្ចប្រជុំជាទៀងទាត់រវាងរដ្ឋបាលរាជធានី ខេត្ត និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ការចូលរួម និងការផ្តល់យោបល់របស់អង្គការសង្គមស៊ីវិលក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំង | រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| | ការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មាននានា និងការរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំនូវបញ្ជីអង្គការសង្គមស៊ីវិលនានាដែលបំពេញការងារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងការសម្របសម្រួល និងកិច្ចសហការក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ | |
| 2.7 | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | |
| 2.7.1 | **ការពង្រឹង និងការពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹង និងការពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតឱ្យបានដល់តំបន់ជនបទ (ស្រុក និងឃុំ)។ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងមហាផ្ទៃ |
| 2.7.2 | **ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យ និងកែសម្រួលប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការសិក្សាអំពីប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងការសិក្សាអំពីគំរូស្តង់ដារដ្ឋាភិបាលឌីជីថលនៅថ្នាក់ក្រោមជាតិ។ រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំ និងពង្រឹងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការប្រាស្រ័យទាក់ទងការងាររដ្ឋបាល សម្របសម្រួលក្នុងការសិក្សា និងរៀបចំគំរូស្តង់ដារដ្ឋាភិបាលឌីជីថលនៅថ្នាក់ក្រោមជាតិ ការរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. និងការចុះគាំទ្រថ្នាក់ក្រោមជាតិអំពីការរៀបចំ និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យនានា ព្រមទាំងគាំទ្រ និងប្រតិបត្តិការប្រព័ន្ធផ្ទុកទិន្នន័យ និងប្រព័ន្ធបណ្តាញសម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប. | លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 2.7.3 | **ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំ និងផ្សព្វផ្សាយឯកសារព័ត៌មាននានាដែលពាក់ព័ន្ធនឹងលិខិតបទដ្ឋានការផ្តល់សេវា ការអនុវត្តគម្រោង ការអនុវត្តថវិកា សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវនានា និងព័ត៌មានផ្សេងទៀតជូនប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអំពីកិច្ចដំណើរការនៃការជ្រើសរើស និងការអនុវត្តគម្រោងពាក់ព័ន្ធទៅនឹងការប្រែប្រួល | លេខាធិការដ្ឋាន គ.ជ.អ.ប. និងរាជធានី ខេត្ត |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| | អាកាសធាតុក្រោមការគាំទ្រថវិកាពី គ.ជ.អ.ប. និងប្រព័ន្ធទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋ និងការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹងគម្រោងនានាក្រោមការដឹកនាំ និងសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។ | |
| **2.8** | **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត** | |
| **2.8.1** | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្ដោតលើការសិក្សា និងរៀបចំបង្កើតអង្គភាពត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត និងរៀបចំនីតិវិធីសម្រាប់ត្រួតពិនិត្យផ្ទៃក្នុង ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាពនៃការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |

*** <u>កំណត់សម្គាល់៖</u> សកម្មភាពជាអាទិភាពពាក់ខ្វះដែលមិនបានរៀបចំតាមលំដាប់លេខរៀងដោយសារសកម្មភាពអាទិភាពមួយចំនួននៃផអ៥ទី១ មិនត្រូវបានយកមកអនុវត្ត ឬបានអនុវត្តចប់រួចហើយ។

តារាងផែនការសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលសមាសភាគ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សកម្មភាពលម្អិត ថវិកា ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវអនុវត្តដែលពាក់ព័ន្ធនឹងសមាសភាគទីពីរនេះ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី២។

## តារាងទី៣ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីពីរ (គិតជាលានរៀល)

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 2.1 | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ | 2,747 |
| 2.2 | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានពិនិត្យ កែសម្រួល និងប្រតិបត្តិការតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព | 105 |
| 2.3 | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព | 53 |
| 2.4 | ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត | 2,385 |
| 2.5 | សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង | 205 |

| លេ.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 2.6 | ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីជានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | 29,248 |
| 2.7 | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | 667 |
| 2.8 | ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត | 80 |
| | **សរុបរួម** | 35,491 |

## តារាងទី៤ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីពីរ

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 2 | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖<br>រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមទម្រង់លក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ | | | | | | |
| 2.1 | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមទម្រង់លក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ | | | | | | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាលក្រុង ស្រុក | 36. ភាគរយសរុបនៃក្រុង ស្រុក ខណ្ឌដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | ភាគរយ | 20% | 20% | 10% | 10% |
| | | 37. មុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសត្រូវបានកំណត់ | លិខិតបទដ្ឋាន | 1 | 1 | | 1 |
| | | 38. ភាគរយសរុបនៃមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដែលមានសេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | ភាគរយ | ៦0% | ៧0% | ៦0% | ១0% |
| | | 39. ទិន្នន័យដើមគ្រាសម្រាប់មុខងារអប់រំត្រូវបានរៀបចំ | របាយការណ៍ | | 1 | 1 | |
| | | 40. ការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល | របាយការណ៍ | | 1 | 1 | |
| | | 41. ការសិក្សាពីលទ្ធភាពបង្កើតការិយាល័យសុខាភិបាលនៅថ្នាក់ក្រុង ស្រុក | របាយការណ៍ | | 1 | | 1 |
| 2.1.2 | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 42. ភាគរយឃុំ សង្កាត់ដែលទទួលបានការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារ | ភាគរយ | 5% | 5% | 2.5% | 2.5% |
| | | 43. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយរាជធានី ខេត្តក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | 100% |
| | | 44. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយក្រុង ស្រុកក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | 100% |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 2.1.3 | ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន | 45. ការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | | 1 | 1 | |
| | | 46. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | | 1 | | 1 |
| 2.1.4 | ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ | 47. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ | របាយការណ៍ | | 1 | | 1 |
| **2.2** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | | | | | | |
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត | 48. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរបស់រដ្ឋបាលខេត្តត្រូវបានរៀបចំ | របាយការណ៍ | | 1 | | 1 |
| 2.3.1 | ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី | 49. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរដ្ឋបាលរាជធានីត្រូវបានរៀបចំ | របាយការណ៍ | | 1 | | 1 |
| **2.4** | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.4.4 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | 50. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត | វេទិកា | 100 | 100 | 50 | 50 |
| | | 51. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលក្រុង ស្រុក | វេទិកា | 776 | 776 | 388 | 388 |
| **2.5** | **សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | |
| 2.5.3 | ការរៀបចំកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 52. ការសិក្សាអំពីលទ្ធភាព និងការរៀបចំកញ្ចប់ថវិកាគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | 1 | |
| **2.6** | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាបាននូវជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 2.6.1 | ការពង្រឹងយន្តការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ | 53. ការសិក្សាអំពីជម្រើសនានាក្នុងការបង្កើតយន្តការផ្តល់ព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិជូនប្រជាពលរដ្ឋ | របាយការណ៍ | 1 | 1 | | 1 |
| | | 54. ភាគរយសរុបនៃឃុំ សង្កាត់ដែលអនុវត្តការងារគណនេយ្យភាពសង្គម | ភាគរយ | 93% | 93% | 93% | 93% |
| | | 55. ការសិក្សា និងរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ត្រូវបានរៀបចំ | របាយការណ៍ | | 1 | | 1 |
| | | 56. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌលើសេវាតាមការិយាល័យច្រកចេញចូលតែមួយ | ភាគរយ | 17% | 17% | 17% | 17% |
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 57. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវបានរៀបចំ | វគ្គ | 1 | 1 | 1 | |
| | | 58. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | បណ្តឹង | 80% | 80% | 80% | 80% |
| | | 59. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | វគ្គ | 1 | 1 | 1 | |
| | | 60. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ | បណ្តឹង | 80% | 80% | 80% | 80% |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | 61. ភាគរយរដ្ឋបាលរាជធានី ខេត្ត ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 50% | 50% | 50% | 50% |
| | | 62. ភាគរយរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 20% | 20% | 20% | 20% |
| **2.7** | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 2.7.1 | ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | 63. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបានតំណភ្ជាប់សេវាអ៊ីនធឺណិត | ភាគរយ | 40% | 60% | 50% | 60% |
| | | 64. ប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល ( ISAF M&E Database, NAD, PID... ) | ប្រព័ន្ធ | 5 | 5 | 2 | 3 |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 65. ការសិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ ( SNA-MIS ) | របាយការណ៍ | | 1 | | 1 |
| | | 66. ការសិក្សាអំពីប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិត្រូវបានអនុវត្ត | របាយការណ៍ | 1 | 1 | | 1 |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 67. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់គេហទំព័របណ្តាញសង្គម និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ ដើម្បីផ្សព្វផ្សាយ និងទទួលព័ត៌មានពាក់ព័ន្ធនានា | ភាគរយ | 20% | 50% | 50% | 50% |
| | | 68. ភាគរយរាជធានី ខេត្ត បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ភាគរយ | 70% | 70% | 70% | 70% |
| 2.8 | **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.8.1 | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 69. ការសិក្សាអំពីលទ្ធភាពនៃការបង្កើតអង្គភាពត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | | 1 | 1 | |
| | | 70. បែបបទ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវបានរៀបចំ | សេចក្ដីណែនាំ | | 1 | | 1 |

# សមាសភាគទីបី ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

## ក. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទីបីគឺ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។

## ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើ សមាសភាគទីបីបានកំណត់នូវលទ្ធផលរំពឹងទុកសរុបចំនួន០៨ សកម្មភាពជាអាទិភាពចំនួន២០ និងសកម្មភាពលម្អិតចំនួន៤៤ រួមបញ្ចូលសូចនាករចំនួន២៦ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងមានថវិកាសរុបចំនួន២០.៧១០លានរៀល ស្មើនឹង៥,១៨លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពទាំងនេះ មានរៀបរាប់ដូចខាងក្រោម៖

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 3.1 | **អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត** | |
| 3.1.1 | **ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ**<br>សកម្មភាពនេះផ្តោតលើការពិនិត្យ និងរៀបចំឡើងវិញនូវអង្គមន្ត្រីរាជការនីមួយៗដែលមានការពាក់ព័ន្ធទៅនឹងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពីអង្គមន្ត្រីរាជការត្រូវបានអនុវត្ត និងរៀបចំកំណត់អំពីក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ឱ្យស័ក្តិសមនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ |
| 3.2 | **ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| 3.2.1 | **ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំ ផ្សព្វផ្សាយ និងការអនុវត្តការពិព័ណ៌នាមុខតំណែងសម្រាប់មុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៅតាមអង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ | ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |
| 3.2.2 | **ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំគោលការណ៍ណែនាំអំពីលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 3.2.3 | **ការពង្រឹងការគ្រប់គ្រងវត្តមានបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវការណែនាំ និងពង្រឹងការត្រួតពិនិត្យវត្តមានបុគ្គលិកថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ | ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 3.2.4 | **ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំ និងពង្រឹងការអនុវត្តនូវក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |
| 3.2.5 | **ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ**<br>សកម្មភាពនេះផ្តោតលើការរៀបចំប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការបំពេញការងាររបស់បុគ្គលិកម្នាក់ៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 3.3 | **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| 3.3.1 | **ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ |
| 3.4 | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | |
| 3.4.1 | **ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ**<br>សកម្មភាពនេះផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការវាយតម្លៃតម្រូវការធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមហាផ្ទៃ |
| 3.4.2 | **ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក**<br>សកម្មភាពនេះផ្តោតលើការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការវិភាគ និងការព្យាករណ៍តម្រូវការធនធានមនុស្ស ដើម្បីរៀបចំផែនការបុគ្គលិក។ | ក្រសួងមហាផ្ទៃ |
| 3.4.3 | **ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំផែនការបុគ្គលិករដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌប្រចាំឆ្នាំ ផ្អែកលើលទ្ធផលនៃការវាយតម្លៃតម្រូវការធនធានមនុស្ស។ | រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| 3.5 | **គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| 3.5.1 | **ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្តោតលើការរៀបចំប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 3.5.4 | **លើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្ដោតលើការផ្សព្វផ្សាយ ការអភិវឌ្ឍសមត្ថភាព និងការអនុវត្តផែនការយុទ្ធសាស្ត្រស្ដីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| 3.6 | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | |
| 3.6.1 | **ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្ដោតលើការពិនិត្យ កែសម្រួលឡើងវិញនូវលិខិតបទដ្ឋាន សេចក្ដីណែនាំបច្ចេកទេសនានាពាក់ព័ន្ធនឹងការកំណត់អំពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព។ | ក្រសួងមហាផ្ទៃ |
| 3.6.2 | **ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត អំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព**<br>សកម្មភាពនេះផ្ដោតលើការអភិវឌ្ឍសមត្ថភាពអង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តក្នុងការអនុវត្តការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់រៀបចំផែនការអភិវឌ្ឍសមត្ថភាព។ | ក្រសួងមហាផ្ទៃ |
| 3.6.3 | **ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**<br>សកម្មភាពនេះផ្ដោតលើការរៀបចំ និងអនុវត្តការវាយតម្លៃជាប្រចាំអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ | រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| 3.6.4 | **ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព**<br>សកម្មភាពនេះផ្ដោតលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងកម្មវិធីអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាដោយមន្ទីរអង្គភាពជំនាញ។ | រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងមន្ទីរជំនាញ |
| 3.7 | **ស្ថាប័នបណ្ដុះបណ្ដាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្ដុះបណ្ដាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| 3.7.1 | **ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន**<br>សកម្មភាពនេះនឹងផ្ដោតលើការជ្រើសរើសបុគ្គលិកប្រកបដោយសមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ដើម្បីបំពេញមុខតំណែងដែលនៅទំនេរសម្រាប់បម្រើការងារនៅសាលាជាតិរដ្ឋបាលមូលដ្ឋាន និងការសាងសង់ និងបំពាក់ឧបករណ៍នានា។ | ក្រសួងមហាផ្ទៃ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 3.7.3 | **ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ**<br>សកម្មភាពនេះត្រូវផ្តោតលើការរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំកម្មវិធីបណ្តុះបណ្តាលជាកាតព្វកិច្ច និងអភិវឌ្ឍសមត្ថភាពផ្សេងៗទៀត។ | ក្រសួងមហាផ្ទៃ |
| **3.8** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | |
| 3.8.2 | **ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា**<br>សកម្មភាពនេះផ្តោតលើការសិក្សា និងកំណត់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធនានា ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សា និងរៀបចំ និងអនុវត្តកម្មវិធីសិក្សាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ន |
| 3.8.3 | **ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា**<br>សកម្មភាពនេះផ្តោតលើការរៀបចំ និងធ្វើបច្ចុប្បន្នភាពឯកសារសម្ភារៈបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន និងស្ថាប័នជំនាញនានា។ | ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ន |

*** <u>**កំណត់សម្គាល់៖**</u> សកម្មភាពជាអាទិភាពពាក់ព័ន្ធដែលមិនបានរៀបចំតាមលំដាប់លេខរៀង ដោយសារសកម្មភាពអាទិភាពមួយចំនួននៃផអ៥ទី១ មិនត្រូវបានយកមកអនុវត្ត ឬបានអនុវត្តចប់រួចហើយ។

តារាងផែនការសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលសមាសភាគ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សកម្មភាពលម្អិត ថវិកា ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវអនុវត្តដែលពាក់ព័ន្ធនឹងសមាសភាគទីបីនេះ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី២។

### តារាងទី៥ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបី

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 3.1 | អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត | - |
| 3.2 | ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 470 |
| 3.3 | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | - |
| 3.4 | តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់ | 56 |
| 3.5 | គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 381 |

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 3.6 | ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់ | 1,488 |
| 3.7 | ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 18,244 |
| 3.8 | កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | 70 |
| | **សរុបរួម** | 20,710 |

## តារាងទី៦ ៖ សូចនាករ និងចំណុចដៅនៃសមាសភាគទីបី

| ក្រូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3 | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមានសីលធម៌វិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ | | | | | | |
| 3.1 | អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត | | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 71. ការសិក្សា និងរៀបចំលិខិតបទដ្ឋាននានាស្តីពីអង្គមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | | 1 | | 1 |
| | | 72. ការសិក្សាអំពីការរៀបចំក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ឱ្យសមស្របនឹងមុខតំណែង និងការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| 3.2 | ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | | | |
| 3.2.1 | ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 73. សេចក្តីណែនាំស្តីពីការពិពណ៌នាអំពីមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈសម្រាប់អង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | សេចក្តីណែនាំ | | អនុម័ត | | 1 |
| 3.2.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 74. គោលការណ៍ណែនាំស្តីពីការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | គោលការណ៍ | | 1 | | 1 |
| 3.2.4 | ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 75. លិខិតបទដ្ឋានស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | អនុម័ត | | 1 |
| 3.2.5 | ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ | 76. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត | ប្រព័ន្ធ | សេចក្តីព្រាង | អនុម័ត | | 1 |
| 3.3 | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3.3.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 77. ការសិក្សា និងការរៀបចំឯកសារទស្សនទានអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ឯកសារទស្សនទាន | | 1 | 1 | |
| 3.4 | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | | | | | | |
| 3.4.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ | 78. សេចក្តីណែនាំស្តីពីការវាយតម្លៃតម្រូវការធនធានមនុស្សត្រូវបានរៀបចំ | សេចក្តីណែនាំ | | សេចក្តីព្រាង | | 1 |
| 3.4.2 | ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | 79. ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | វគ្គ | | អនុវត្ត | | 1 |
| 3.4.3 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 80. ភាគរយរដ្ឋបាលថ្នាក់រាជធានី ខេត្តបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | | 100% | | 100% |
| | | 81. ភាគរយរដ្ឋបាលថ្នាក់ក្រុង ស្រុកបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | | 100% | | 100% |
| 3.5.1 | ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 82. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | | 1 | | 1 |
| 3.5 | **គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.5.4 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 83. ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត ផ្សព្វផ្សាយ និងអនុវត្ត | ផែនការ | សេចក្តីព្រាង | អនុម័ត | 1 | |
| | | 84. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ភាគរយ | 27.51% | 27.51% | | 27.51% |
| | | 85. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 23.58% | 23.58% | | 23.58% |
| 3.6 | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3.6.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 86. សេចក្តីណែនាំស្តីពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានពិនិត្យ និងកែសម្រួល | សេចក្តីណែនាំ | | 1 | | 1 |
| 3.6.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 87. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | វគ្គ | | 1 | | 1 |
| 3.6.3 | ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 88. របាយការណ៍វាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | | 1 | | 1 |
| 3.6.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 89. ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | | 100% | | 100% |
| | | 90. ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | | 90% | | 90% |
| | | 91. ភាគរយនៃសកម្មភាពអភិវឌ្ឍសមត្ថភាពដែលបានគ្រោងក្នុងផែនការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | ភាគរយ | | 80% | 40% | 40% |
| **3.7** | **ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.7.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 92. ភាគរយអគារនៃសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានសាងសង់ | ភាគរយ | | 60% | 30% | 30% |
| | | 93. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់គ្រូបណ្តុះបណ្តាល និងបុគ្គលិករបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | វគ្គ | 4 | 4 | 2 | 2 |
| 3.7.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 94. ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានរៀបចំ | វគ្គ | 35 | 35 | 15 | 20 |
| **3.8** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3.8.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 95. លិខិតបទដ្ឋានស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | 1 | | 1 |
| 3.8.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា | 96. ចំនួនសៀវភៅគោលត្រូវបានរៀបចំ | ក្បាល | 5 | 4 | | 4 |

## សមាសភាគទីបួន ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកាថ្នាក់ក្រោមជាតិ

### ក. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទីបួនគឺ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានា ដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើ សមាសភាគទីបួនបានកំណត់នូវលទ្ធផលរំពឹងទុកសរុបចំនួន០៩ សកម្មភាពជាអាទិភាពចំនួន១៦ និងសកម្មភាពលម្អិតចំនួន៤៦ រួមបញ្ចូលសូចនាករចំនួន៣១ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងមានថវិកាសរុបចំនួន៧.១២៩.២៩៣លានរៀល ស្មើនឹង១.៧៨២លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពទាំងនេះ មានរៀបរាប់ដូចខាងក្រោម៖

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| **4.1** | **កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សុីគ្នា ដោយផ្អែកលើចរិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** | |
| 4.1.1 | ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការបន្សុីគ្នារវាងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។ | ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.1.3 | ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សាអំពីការរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា និងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសង្គម។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យ និងការកែសម្រួលប្រព័ន្ធទិន្នន័យនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| | បរិយាប័ន្ន សមធម៌ និងសង្គម ដូចជាប្រព័ន្ធទិន្នន័យស្តីពីគម្រោង និងប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ជាដើម ព្រមទាំងការប្រមូល និងផលិត ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ឆ្នាំ២០២៣។ | |
| **4.2** | **ការអនុវត្តមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥)<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំ និងអនុវត្តបែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការពង្រឹងការអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.2.2 | ការធ្វើវិមជ្ឈការ និងការពង្រឹងការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យមើលឡើងវិញ និងការរៀបចំលិខិតបទដ្ឋាននានាអំពីការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចការលទ្ធកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ |
| **4.3** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានស្តីពីការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែលមានស្រាប់របស់រាជធានី ខេត្ត។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.3.2 | ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់<br>សកម្មភាពនេះផ្តោតជាសំខាន់លើការបង្កើនអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| **4.4** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់យន្តការច្រកចេញចូលតែមួយ និងអង្គភាពទទួលខុសត្រូវលើការប្រមូលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **4.5** | **ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់** | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងការអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពន្លឿនការផ្ទេរទ្រព្យសម្បត្តិរដ្ឋពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមមុខងារដែលបានផ្ទេរ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **4.6** | **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ** | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក<br>សកម្មភាពនេះផ្តោតជាសំខាន់លើការអត្រាផ្ទេរធនធានពីថវិកាជាតិទៅឱ្យមូលនិធិក្រុង ស្រុក និងការសិក្សាអំពីរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការវិភាជធនធានពីមូលនិធិក្រុង ស្រុក។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ |
| 4.6.2 | ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តច្បាស់លាស់មួយលើការគ្រប់គ្រង និងការបែងចែកមូលនិធិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន គ.ជ.អ.ប. |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងសេវាសង្គម អនាម័យ និងបរិស្ថាន។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.7 | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំថែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និង កែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋាននានាដែលមានស្រាប់នាពេលបច្ចុប្បន្នពាក់ព័ន្ធនឹងការផ្ទេរ ការចាត់ចែង និងការប្រើប្រាស់ធនធានមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.8 | **ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត** | |
| 4.8.1 | ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សា និងវាយតម្លៃលើការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| 4.8.3 | ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស<br>សកម្មភាពនេះផ្តោតជាសំខាន់លើការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានសម្រាប់បង្កើតយន្តការមូលនិធិភាតរភាព។ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| **4.9** | **ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព** | |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>សកម្មភាពនេះផ្តោតជាសំខាន់លើ (១) ការសិក្សា និងរៀបចំអំពីក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និង(២) ការពង្រឹងការអនុវត្តការវិនិយោគក្រោម៥លានដុល្លារនៅរដ្ឋបាលរាជធានី ខេត្ត។ | លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ |

*** <u>កំណត់សម្គាល់៖</u> សកម្មភាពជាអាទិភាព៣ខ្ទង់ដែលមិនបានរៀបចំតាមលំដាប់លេខរៀង ដោយសារសកម្មភាពអាទិភាពមួយចំនួននៃផអ៥ទី១ មិនត្រូវបានយកមកអនុវត្ត ឬបានអនុវត្តចប់រួចហើយ។

តារាងផែនការសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលសមាសភាគ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព សកម្មភាពលម្អិត ថវិកា ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវអនុវត្តដែលពាក់ព័ន្ធនឹងសមាសភាគទីបួននេះ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី២។

### តារាងទី៧៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីបួន (គិតជាលានរៀល)

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 4.1 | កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សីុគ្នា ផ្អែកលើចរិតលក្ខណៈនិងប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របជាមួយគោលនយោបាយអាទិភាពថ្នាក់ជាតិ និងទិសដៅនៃកម្មវិធីកំណែទម្រង់សំខាន់ៗ និងផ្អែកលើទិន្នន័យច្បាស់លាស់ | 767 |
| 4.2 | ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | - |
| 4.3 | ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត | - |
| 4.4 | ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត | - |
| 4.5 | ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់ | - |

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 4.6 | មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ | 4,314,499 |
| 4.7 | មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | 2,797,018 |
| 4.8 | ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏ច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត | 17,000 |
| 4.9 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 9 |
| | **សរុបរួម** | 7,129,293 |

# តារាងទី៨ ៖ សូចនាករ និងចំណុចដៅសមាសភាគទីបួន

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 4 | ទិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | | | | | | |
| 4.1 | កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបន្សុីគ្នា ដោយផ្អែកលើចរិតលក្ខណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | | | | | | |
| 4.1.1 | ការបន្សុីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 97. ភាគរយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រទៅលើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន | ភាគរយ | | 100% | 100% | 100% |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 98. ប្រព័ន្ធទិន្នន័យស្តីពីព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ និងកែសម្រួល (SPD) | ទិន្នន័យ | បានរៀបចំកែសម្រួល | 1 | 1 | |
| | | 99. ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ត្រូវបានប្រមូលផលិត និងចែករំលែក (CDB ឆ្នាំ២០២៣) | ទិន្នន័យ | | 1 | 1 | |
| | | 100. ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីមន្ទីរផែនការអំពីដំណើរការ និងវិធីសាស្ត្រកសាងផែនការនៅថ្នាក់ក្រោមជាតិ និងវិធីសាស្ត្រកែច្នៃ វិភាគ និងផលិតឯកសារព័ត៌មាន និងទិន្នន័យនានា | វគ្គ | 2 | 3 | 1 | 2 |
| 4.2 | ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | | | | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 101. ចំនួនរដ្ឋបាលរាជធានី ខេត្ត ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | រាជធានី ខេត្ត | 25 | 25 | 25 | 25 |
| | | 102. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដែលត្រូវ | លិខិតបទដ្ឋាន | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | បានធ្វើប្រតិភូកម្មទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត | | | | | |
| | | 103. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ចំណាយរបស់ថ្នាក់ក្រុង ស្រុកដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរតនាគារខេត្ត | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 104. ក្របខ័ណ្ឌរួមស្តីពីការធ្វើរបាយការណ៍ និងការត្រួតពិនិត្យតាមដានចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 105. ក្របខ័ណ្ឌរួមមួយស្តីពីការវាយតម្លៃចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | | 1 |
| 4.3 | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់ | 106. លិខិតបទដ្ឋានស្តីពីការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែលមានស្រាប់របស់រាជធានី ខេត្តត្រូវបានរៀបចំ និងអនុវត្ត | លិខិតបទដ្ឋាន | | 1 | 1 | |
| | | 107. ចំណូលសារពើពន្ធរបស់រាជធានី ខេត្តមានការកើនឡើងធៀបនឹងឆ្នាំ២០២៣ | ចំណូល | 530លានដុល្លារ | កើនឡើង | | 1 |
| 4.3.2 | ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | 108. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក | ភាគរយ | 4% | 4% | 4% | 4% |
| | | 109. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលឃុំ សង្កាត់ | ភាគរយ | 5% | 6% | 6% | 6% |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 4.4 | ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍មុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត | | | | | | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 110. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ប្រព័ន្ធ | អនុវត្ត | អនុវត្ត | | 1 |
| | | 111. ភាគរយនៃការទូទាត់តាមប្រព័ន្ធឌីជីថលសម្រាប់អង្គភាព/ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ភាគរយ | សាកល្បង | សេវាចំនួន ១០%បាន អនុវត្ត | | 1 |
| | | 112. ការសិក្សាអំពីជម្រើសនានានៃការប្រើប្រាស់ចំណូលដែលទទួលបានកម្រៃពីអ្នកប្រើប្រាស់សេវាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| 4.5 | ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការច្បាស់លាស់ | | | | | | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 113. ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរ | ការផ្ទេរ | | អនុវត្ត | | 1 |
| | | 114. សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | សេចក្តីណែនាំ | | 1 | 1 | |
| | | 115. ការបែងចែកចំណូលពីទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ការបែងចែក | | អនុវត្ត | | 1 |
| | | 116. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលរាជធានី ខេត្តត្រូវបានពង្រឹងការអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 117. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | | 1 |
| **4.6** | **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិខ្លួនទៅ** | | | | | | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក | 118. អត្រាផ្ទេរធនធានពីថវិការដ្ឋទៅឱ្យមូលនិធិក្រុង ស្រុក | អត្រា | 1.5 | 1.6 | 1.6 | 1.6 |
| | | 119. ការសិក្សាអំពីប្រភេទចំណូលមិនមែនសារពើពន្ធដាក់លាក់មួយចំនួនដែលត្រូវបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក | របាយការណ៍ | | 1 | | 1 |
| 4.6.2 | ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 120. ការសិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | | រៀបចំ | | 1 |
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា | 121. លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងសេវាសង្គម អនាម័យ និងបរិស្ថាន | លិខិតបទដ្ឋាន | | 1 | | 1 |
| **4.7** | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | 122. ការសិក្សាលើការរៀបចំការដាក់បញ្ចូលធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារទៅក្នុងគម្រោងថវិកាឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | | រៀបចំ | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 4.8 | ក្របខ័ណ្ឌសម្រាប់ផ្តល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិច្បាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត | | | | | | |
| 4.8.1 | ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | 123. ការសិក្សា និងវាយតម្លៃលើការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| | | 124. គោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានពិនិត្យ និងកែសម្រួល | គោលការណ៍ | | 1 | | 1 |
| 4.8.3 | ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាគភាព និងកញ្ចប់ថវិកាពិសេស | 125. លិខិតបទដ្ឋានសម្រាប់បង្កើតយន្តការមូលនិធិភាគភាពត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | 1 | |
| 4.9 | ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព | | | | | | |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន និងពង្រឹងការគ្រប់គ្រងការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 126. សិក្សា និងរៀបចំអំពីក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | របាយការណ៍ | | 1 | | 1 |
| | | 127. នីតិវិធីសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្តីណែនាំ | | 1 | 1 | |

# សមាសភាគទីប្រាំ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

## ក. សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃសមាសភាគទីប្រាំគឺ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ខ. លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព

ដើម្បីសម្រេចបាននូវសមិទ្ធផលខាងលើ សមាសភាគទីប្រាំបានកំណត់នូវលទ្ធផលរំពឹងទុកសរុបចំនួន០៤ សកម្មភាពជាអាទិភាពចំនួន១១ និងសកម្មភាពលម្អិតចំនួន៤១ រួមបញ្ចូលសូចនាករចំនួន១២ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០២៤ និងមានថវិកាសរុបចំនួន៣១.៨២៦លានរៀល ស្មើនឹង៨លានដុល្លារអាមេរិក។

លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពទាំងនេះ មានរៀបរាប់ដូចខាងក្រោម៖

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 5.1 | **ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព** | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច<br>សកម្មភាពនេះផ្តោតជាសំខាន់លើការកំណត់មុខងារជាកាតព្វកិច្ច និងរៀបចំសេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី និងបែបបទនៃការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស<br>សកម្មភាពនេះផ្តោតជាសំខាន់លើការកំណត់មុខងារជាជម្រើស និងរៀបចំសេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំផ្សព្វផ្សាយ និងចែករំលែកនូវមេរៀនបទពិសោធ នៅក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការផ្តួចផ្តើមគំនិតប្រកបដោយភាពច្នៃប្រតិដ្ឋក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារជាជម្រើសនានា។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 5.2 | **យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាបាលការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | |
| 5.2.1 | **ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអភិវឌ្ឍសមត្ថភាពដល់រាជធានី ខេត្តអំពីការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។ | ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្ត |
| 5.2.2 | **ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រឹងការអនុវត្តការផ្តល់សេវារដ្ឋបាលរបស់ការិយាល័យសេវាច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ និងផ្សព្វផ្សាយ និងអភិវឌ្ឍសមត្ថភាពដល់ក្រុង ស្រុក ខណ្ឌអំពីការផ្តល់សេវារដ្ឋបាលតាមរយៈការិយាល័យសេវាច្រកចេញចូលតែមួយ។ | ក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| 5.2.3 | **ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពង្រីក និងពង្រឹងកិច្ចប្រតិបត្តិការនៃកម្មវិធីព័ត៌មានវិទ្យាសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការផ្តល់សេវារដ្ឋបាល។ | ក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ |
| 5.3 | **យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត** | |
| 5.3.1 | **ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការផ្សព្វផ្សាយអំពីការរៀបចំទិន្នន័យមូលដ្ឋានអាជីវកម្ម សិប្បកម្ម សេវាកម្ម សហគមន៍ផលិតនានា និងរៀបចំចងក្រង ការធ្វើបច្ចុប្បន្នភាពជាប្រចាំ និងការផ្សព្វផ្សាយអំពីការរៀបចំទិន្នន័យមូលដ្ឋានអាជីវកម្ម សិប្បកម្ម សេវាកម្ម សហគមន៍ផលិតនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | រដ្ឋបាលរាជធានី ខេត្ត |
| 5.3.2 | **ការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការគាំទ្រការលើកកម្ពស់វិស័យសេវាសង្គម កិច្ចគាំពារកុមារ លើកកម្ពស់អាហារូបត្ថម្ភនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ | ដៃគូអភិវឌ្ឍ ( UNICEF, WB, GIZ and SDC ) |

| កូដ | លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|
| 5.4 | ***ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ*** | |
| 5.4.1 | **ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សា និងរៀបចំលិខិតបទដ្ឋានស្តីពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនៅគ្រប់រដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 5.4.2 | **ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យ និងកែសម្រួលបទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងការងារពាក់ព័ន្ធផ្សេងទៀត។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 5.4.3 | **ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការសិក្សា និងរៀបចំទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ សិក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីឃ្លាំមើលបរិស្ថាន និងសង្គម។ | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| 5.4.4 | **ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា**<br>សកម្មភាពនេះផ្តោតជាសំខាន់លើការពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម សេវាសង្គម។ល។ រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីដំណើរការ និងវិធីសាស្ត្រនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ ការលើកកម្ពស់សេវាសង្គម។ល។ | លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត |

*** <u>កំណត់សម្គាល់៖</u> សកម្មភាពជាអាទិភាពពាក់ព័ន្ធខាងលើ... 

តារាងផែនការសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤ រួមបញ្ចូលសមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព សកម្មភាពលម្អិត ថវិកា ក្របខ័ណ្ឌពេលវេលា និងស្ថាប័នទទួលខុសត្រូវអនុវត្ត ដែលពាក់ព័ន្ធនឹងសមាសភាគទីប្រាំនេះ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី២។

**តារាងទី៩ ៖ លទ្ធផលរំពឹងទុក និងថវិកានៃសមាសភាគទីប្រាំ (គិតជាលានរៀល)**

| ល.រ. | លទ្ធផលរំពឹងទុក | ថវិកា |
|---|---|---|
| 5.1 | ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព | 679 |
| 5.2 | យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាពគណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 997 |
| 5.3 | យុទ្ធសាស្ត្រលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនត្រូវបានពិនិត្យ កែសម្រួល និងជំរុញការអនុវត្ត | 27,365 |
| 5.4 | ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានាត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 2,786 |
| | **សរុបរួម** | 31,826 |

## តារាងទី១០ ៖ សូចនាករ និងចំណុចដៅសមាសភាគទី៥

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 5 | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | | | | | | |
| 5.1 | ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព | | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 128. មេរៀនបទពិសោធស្តីពីការអនុវត្តមុខងារជា កាតព្វកិច្ចត្រូវបានរៀបចំ | ករណីសិក្សា | | 1 | | 1 |
| | | 129. ចំនួនភាគរយសរុបនៃមុខងារជាកាតព្វកិច្ចដែលមានសេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ | ភាគរយ | 70% | 90% | 80% | 90% |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 130. នីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | បានសិក្សា | បានកែសម្រួល | 1 | |
| | | 131. នីតិវិធីសម្រាប់អនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | បានសិក្សា | បានកែសម្រួល | 1 | |
| 5.2 | យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាថាការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួលឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងធំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | | | | | | |
| 5.2.1 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | 132. បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 133. សេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគនៅថ្នាក់រាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្តីណែនាំ | | 1 | 1 | |
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | 134. ការផ្តល់សេវាក្នុងវិស័យមួយចំនួនបានផ្តល់តាមប្រព័ន្ធអនឡាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង | ការផ្តល់សេវា | 3 | 5 | | 1 |
| **5.4** | **ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 135. សេចក្តីណែនាំស្តីពីការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | សេចក្តីណែនាំ | | 1 | | 1 |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 136. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | សៀវភៅណែនាំ | សេចក្តីព្រាង | អនុម័ត | 1 | |
| 5.4.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 137. ការសិក្សា និងរៀបចំទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ និងអនុវត្ត | របាយការណ៍ | បានសិក្សា | អនុវត្ត | 1 | |
| 5.4.4 | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 138. លិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាប័ន្ន | លិខិតបទដ្ឋាន | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | សមធម៌សង្គម និងសេវាសង្គម ត្រូវបានពិនិត្យ និងកែសម្រួល | | | | | |
| | | 139. ចំនួនភាគរយនៃគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្តដោយផ្តោតលើការបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានៅក្នុងសហគមន៍មូលដ្ឋាន | ភាគរយ | 20% | 20% | 10% | 10% |

## III. ថវិកាសម្រាប់គាំទ្រ ផ.ស.ថ. ឆ្នាំ២០២៤

### ក. ផែនការចំណាយរួម

ថវិកាចំណាយសរុបរបស់ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. មានសង្ខេបដូចនៅក្នុងតារាងទី១១ ខាងក្រោម។ ក្នុងឆ្នាំ២០២៤ ថវិកាប៉ាន់ស្មានសរុបនៃ ផ.ស.ថ. មានចំនួន**៧.២៣០.២៨១លានរៀល** ស្មើនឹង **១.៨០៧,៥៧លានដុល្លារអាមេរិក** ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន**៧.១៣៤.៧៤៧លានរៀល** ស្មើនឹង**១.៧៨៣,៦៨លានដុល្លារអាមេរិក (ស្មើនឹង៩៨,៦៨%)** និងថវិកាកម្ចីនិងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍនានាមានចំនួន**៩៥.៥៣៤លានរៀល** ស្មើនឹង**២៣,៨៨លានដុល្លារអាមេរិក (ស្មើនឹង ១,៣២%)** នៃថវិកាសរុប។ ថវិកាចំណាយសរុបនេះ រួមបញ្ចូលទាំងថវិកាចំណាយសម្រាប់គាំទ្រដល់ការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាចំណាយសម្រាប់គាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**តារាងទី១១ ៖ ផែនការចំណាយសរុបតាមសមាសភាគសម្រាប់ ឆ្នាំ២០២៤ (ជាលានរៀល)**

| សមាសភាគ | ប្រភេទថវិកាចំណាយ | ថវិការាជរដ្ឋាភិបាល | ថវិកាកម្ចី | ថវិកាជំនួយឥតសំណង | សរុប |
|---|---|---|---|---|---|
| ១ | ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ | 8,731 | 0 | 4,230 | 12,961 |
| ២ | បេនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | 8,899 | 0 | 26,593 | 35,491 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 2,474 | 18,236 | 0 | 20,710 |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 7,112,293 | 17.000 | 0 | 7,129,293 |
| ៥ | ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន | 2,351 | 26,982 | 2,494 | 31,826 |
| | **សរុបរួម** | 7,134,747 | 62,218 | 33,316 | 7,230,281 |
| | **គិតជាភាគរយ** | 98.68% | 0.86% | 0.46% | 100.00% |

### ខ. ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ធនធានហិរញ្ញវត្ថុដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ថវិការាជធានី ខេត្ត មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ចំណូលពន្ធ ចំណូលមិនមែនសារពើពន្ធ មូលនិធិមានភ្ជាប់លក្ខខណ្ឌ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាផ្ទេរសម្រាប់ការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌចំនួន២០វិស័យ និងថវិកាឧបត្ថម្ភបន្ថែមពីថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ឃុំ សង្កាត់។

ក្នុងឆ្នាំ២០២៤ ធនធានហិរញ្ញវត្ថុសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួន**៧.១១១.២០៨លានរៀល** ស្មើនឹង**១.៧៣៤លានដុល្លារអាមេរិក** ក្នុងនោះថវិការាជធានី ខេត្តមានចំនួន**៣.៥៦៣.៤៧៥លានរៀល** ស្មើនឹង**៨៦៩លានដុល្លារ** ថវិកាក្រុង ស្រុក មានចំនួន**២.២៨៨.០១៧លានរៀល** ស្មើនឹង**៥៥៨លានដុល្លារ** និងថវិកាឃុំ សង្កាត់មានចំនួន**១.២៥៩.៧១៧លានរៀល** ស្មើនឹង**៣០៧លានដុល្លារអាមេរិក**។ ចំណូលពន្ធបែកចែកពីរដ្ឋបាលខេត្តដល់រដ្ឋបាលក្រុង ស្រុកមានអត្រា ៤% និងឃុំ សង្កាត់មានអត្រា៦%។ ធនធានបន្ថែមពីថ្នាក់ជាតិដល់ឃុំសង្កាត់សម្រាប់ចំណាយអភិវឌ្ឍមានចំនួន១% នៃចំណូលចរន្តថវិកាជាតិ។

**តារាងទី១២ ៖ ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤ (ជាលានរៀល)**

| ធនធានហិរញ្ញវត្ថុ | ឆ្នាំ២០២៤ | |
|---|---|---|
| | រៀល | ដុល្លារអាមេរិក |
| **ក. រាជធានី ខេត្ត** | | |
| ១. ចំណូលសារពើពន្ធ | 2,214,721,000,000 | 540,175,854 |
| ២. ចំណូលមិនមែនសារពើពន្ធ | 238,579,000,000 | 58,190,000 |
| ៣. ចំណូលឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ | 1,110,174,800,000 | 270,774,341 |
| *- ឧបត្ថមធនដល់រាជធានី (សម្រាប់ខណ្ឌ-ការិយាល័យជំនាញទាំង២០)* | *15,170,000,000* | *3,700,000* |
| *- មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (សម្រាប់អនុវត្តមុខងារអប់រំ)* | *83,509,200,000* | *20,368,098* |
| *- មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (សម្រាប់អនុវត្តមុខងារសុខាភិបាល)* | *887,010,000,000* | *216,343,902* |
| *- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ* | *124,485,600,000* | *30,362,341* |
| សរុបរង | 3,563,474,800,000 | 869,140,195 |
| **ខ. ក្រុង ស្រុក** | | |
| **១. ចំណូលពីថវិកាជាតិ** | **2,263,284,500,000** | **552,020,610** |
| ១.១ ចំណូលមិនមែនសារពើពន្ធ | 14,834,000,000 | 3,618,049 |
| ១.២ ចំណូលឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ | 2,248,450,500,000 | 548,402,561 |
| *- ឧបត្ថមធនដល់រដ្ឋបាលក្រុង ស្រុកសម្រាប់ការិយាល័យជំនាញទាំង២០* | *144,312,000,000* | *35,198,049* |
| *- មូលនិធិក្រុង ស្រុក* | *409,030,000,000* | *99,763,415* |
| *- មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (សម្រាប់អនុវត្តមុខងារអប់រំ)* | *1,666,768,500,000* | *406,528,902* |
| *- ចំណូលពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ* | *20,340,000,000* | *4,960,976* |
| *- ចំណូលមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ* | *8,000,000,000* | *1,951,220* |
| **២. ចំណូលឧបត្ថម្ភពីរដ្ឋបាលខេត្ត** | **24,732,000,000** | *6,032,195* |
| ២.១ ចំណូលចែករំលែកពីចំណូលសារពើរបស់រដ្ឋបាលខេត្ត (៤%)* | 24,732,000,000 | 6,032,195 |
| សរុបរង | 2,288,016,500,000 | 558,052,805 |
| **ខ.១ ធនធានអភិវឌ្ឍរបស់រដ្ឋបាលក្រុង ស្រុក** | | |
| -ធនធានសមាសភាពអភិវឌ្ឍមូលដ្ឋាននៃមូលនិធិក្រុង ស្រុក | 167,025,000,000 | 40,737,805 |
| -ចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្ត* | 24,732,000,000 | 6,032,195 |
| សរុបធនធានអភិវឌ្ឍរបស់រដ្ឋបាលក្រុង ស្រុក | 191,757,000,000 | 46,770,000 |
| -ធនធានអភិវឌ្ឍមូលដ្ឋានជាមធ្យម/ក្រុង ស្រុក | 988,438,144 | 241,082 |
| **គ. ឃុំ សង្កាត់** | | |
| **១. ចំណូលពីថវិកាជាតិ** | **1,150,399,000,000** | **280,585,122** |
| *- មូលនិធិឃុំ សង្កាត់* | *894,755,000,000* | *218,232,927* |
| *- ឧបត្ថម្ភធនបន្ថែមពីថ្នាក់ជាតិ ១%* | *255,644,000,000* | *62,352,195* |

| ធនធានហិរញ្ញវត្ថុ | ឆ្នាំ២០២៤ | |
|---|---|---|
| | រៀល | ដុល្លារអាមេរិក |
| ២. ចំណូលឧបត្ថម្ភពីរដ្ឋបាលរាជធានី ខេត្ត | 109,318,000,000 | 26,662,927 |
| *- ចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត (៦%)* | *109,318,000,000* | *26,662,927* |
| សរុបរង | 1,259,717,000,000 | 307,248,049 |
| **គ.១ ធនធានអភិវឌ្ឍរបស់រដ្ឋបាលឃុំ សង្កាត់** | | |
| -ធនធានសមាសភាពអភិវឌ្ឍមូលដ្ឋាននៃមូលនិធិឃុំ សង្កាត់ | 325,277,000,000 | 79,335,854 |
| -ឧបត្ថម្ភបន្ថែមពីថ្នាក់ជាតិ ១% | 255,644,000,000 | 62,352,195 |
| -ចំណូលចែករំលែកពីចំណូលពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត (៦%) | 109,318,000,000 | 26,662,927 |
| សរុបធនធានអភិវឌ្ឍរបស់រដ្ឋបាលឃុំ សង្កាត់ | 690,239,000,000 | 168,350,976 |
| -ធនធានអភិវឌ្ឍមូលដ្ឋានជាមធ្យម/ឃុំ សង្កាត់ | 417,820,218 | 101,907 |
| សរុបចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 7,111,208,300,000 | 1,734,441,049 |
| * ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនទាន់បានវិភាជ និងជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុកនៅឡើយ។ | | |

## គ. ថវិកាចំណាយសម្រាប់គាំទ្រសកម្មភាពស្នូលនៃកំណែទម្រង់

ក្នុងថវិកាប៉ាន់ស្មានសរុបនៃ ផ.ស.ថ. ឆ្នាំ២០២៤ ចំនួន**១១៩.០៧៣លានរៀល ស្មើនឹង៣០លានដុល្លារអាមេរិក** រួមមានសកម្មភាពស្នូលនៃកំណែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានចំនួន**២៣.៥៣៩លានរៀល ស្មើនឹង៦លានដុល្លារអាមេរិក** និងថវិកាសកម្មភាពជាក់លាក់របស់គម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍគាំទ្រទៅលើកំណែទម្រង់ស្នូលមានចំនួន**៩៥.៥៣៤លានរៀល ស្មើនឹង ២៤លានដុល្លារអាមេរិក**។

### តារាងទី១៣ ៖ ផែនការថវិកាចំណាយសរុបទៅលើសកម្មភាពស្នូលនៃកំណែទម្រង់

| ល.រ. | ស្ថាប័ន | ថវិកា (លានរៀល) | ថវិកា (លានដុល្លារអាមេរិក) |
|---|---|---|---|
| ១ | ស្ថាប័នរាជរដ្ឋាភិបាល | 23,539 | 6 |
| | – ក្រសួង ស្ថាប័ន | 11,043 | 2.76 |
| | – រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | 12,496 | 3.12 |
| ២ | គម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍ | 95,534 | 24 |
| | **សរុបរួម** | 119,073 | 30 |

## តារាងទី១៤ ៖ ផែនការថវិកាចំណាយតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅលើសកម្មភាពស្នូលរបស់កំណែទម្រង់

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកា (លានរៀល) |
|---|---|---|
| | ក. ក្រសួង ស្ថាប័ន | |
| ១. | លេខាធិការដ្ឋាន គ.ជ.អ.ប. | 8,550 |
| ២. | ក្រសួងមហាផ្ទៃ | 374 |
| ៣. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 248 |
| ៤. | ក្រសួងមុខងារសាធារណៈ | 60 |
| ៥. | ក្រសួងផែនការ | 99 |
| ៦. | ក្រសួងកិច្ចការនារី | 275 |
| ៧. | ក្រសួងសាធារណការ និងដឹកជញ្ជូន | 80 |
| ៨. | ក្រសួងបរិស្ថាន | 44 |
| ៩. | ក្រសួងទេសចរណ៍ | 60 |
| ១០. | ក្រសួងពាណិជ្ជកម្ម | 75 |
| ១១. | ក្រសួងធនធានទឹក និងឧតុនិយម | 35 |
| ១២. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 42 |
| ១៣. | ក្រសួងរ៉ែ និងថាមពល | 68 |
| ១៤. | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ | 78 |
| ១៥. | ក្រសួងសុខាភិបាល | 50 |
| ១៦. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 122 |
| ១៧. | ក្រសួងអប់រំ យុវជន និងកីឡា | 200 |
| ១៨. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 79 |
| ១៩. | ក្រសួងអភិវឌ្ឍន៍ជនបទ | 178 |
| ២០. | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 75 |
| ២១. | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 51 |
| ២២. | ក្រសួងព័ត៌មាន | 200 |
| | **សរុបរង (ក)** | **11,043** |
| | ខ. រាជធានី ខេត្ត (រួមបញ្ចូលថវិកាក្រុង ស្រុក ខណ្ឌ) | |
| ១. | បន្ទាយមានជ័យ | 322 |
| ២. | បាត់ដំបង | 824 |
| ៣. | កំពង់ចាម | 771 |
| ៤. | កំពង់ឆ្នាំង | 224 |
| ៥. | កំពង់ស្ពឺ | 291 |
| ៦. | កំពង់ធំ | 771 |
| ៧. | កំពត | 797 |
| ៨. | កណ្តាល | 1,591 |

| ល.រ. | ស្ថាប័នអនុវត្ត | ថវិកា (លានរៀល) |
|---|---|---|
| ៩. | កោះកុង | 621 |
| ១០. | ក្រចេះ | 412 |
| ១១. | មណ្ឌលគិរី | 252 |
| ១២. | រាជធានីភ្នំពេញ | 2,238 |
| ១៣. | ព្រះវិហារ | 183 |
| ១៤. | ព្រៃវែង | 298 |
| ១៥. | ពោធិ៍សាត់ | 224 |
| ១៦. | រតនគិរី | 177 |
| ១៧. | សៀមរាប | 331 |
| ១៨. | ព្រះសីហនុ | 410 |
| ១៩. | ស្ទឹងត្រែង | 243 |
| ២០. | ស្វាយរៀង | 351 |
| ២១. | តាកែវ | 306 |
| ២២. | ឧត្តរមានជ័យ | 188 |
| ២៣. | កែប | 37 |
| ២៤. | ប៉ៃលិន | 265 |
| ២៥. | ត្បូងឃ្មុំ | 369 |
| | សរុបរង (ខ) | 12,496 |
| | **សរុបរួម** | **23,539** |

## តារាងទី១៥ ៖ ថវិកាកម្មវិធីនៃគម្រោង គម្រោងហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍ (គិតជាលានរៀល)

| ល.រ | គម្រោង កម្មវិធី | ដៃគូ | ប្រភេទថវិកា | | | |
|---|---|---|---|---|---|---|
| | | | ការវិនិយោគថ្នាក់ក្រោមជាតិ | ការគ្រប់គ្រងគម្រោង | សកម្មភាពស្នូលនៃកំណែទម្រង់ | សរុប (លានរៀល) |
| ១ | ការលើកកម្ពស់អាហារូបត្ថម្ភ (CNP) | WB | 21,991 | 4,991 | 0 | 26,982 |
| ២ | ការអភិវឌ្ឍសមត្ថភាពដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) | ADB, RGC | 18,119 | 117 | 0 | 18,236 |
| ៣ | ការគាំទ្រមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) | ADB | 17,000 | 0 | 0 | 17,000 |
| | **សរុប** | | 57,110 | 5,108 | 0 | 62,218 |

## តារាងទី១៦ ៖ ថវិកាជំនួយឥតសំណងនៃគម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍ (គិតជាលានរៀល)

| ល.រ | គម្រោង កម្មវិធី | ដៃគូ | ប្រភេទថវិកា | | | |
|---|---|---|---|---|---|---|
| | | | ការវិនិយោគថ្នាក់ក្រោមជាតិ | ការគ្រប់គ្រងគម្រោង | សកម្មភាពស្នូលនៃកំណែទម្រង់ | សរុប (លានរៀល) |
| ១ | ពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ (STAD) | | 0 | 0 | 2,915 | 2,915 |
| ២ | ការគាំទ្រការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ (ISAF) | WB | 0 | 0 | 10,050 | 10,050 |
| ៣ | លើកកម្ពស់ការងារគណនេយ្យភាពសង្គមផ្នែកតម្រូវការ (ISAF-CSOs) | WB | 0 | 0 | 16,542 | 16,542 |
| ៤ | នវានុវត្តន៍នៃការផ្គត់ផ្គង់ទឹកស្អាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ (LGCC-WRP) | UNCDF | 0 | 0 | 394 | 394 |
| ៥ | ការលើកកម្ពស់វិស័យសេវាសង្គម | UNICEF | 0 | 300 | 0 | 300 |
| ៦ | លើកកម្ពស់កិច្ចគាំពារកុមារ | UNICEF | 0 | 0 | 0 | 0 |
| ៧ | កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា (ISD) | GIZ | 0 | 0 | 0 | 0 |
| ៨ | ការរៀបចំយន្តការ និងសៀវភៅណែនាំស្តីពីមូលនិធិវិនិយោគប្រែប្រួលអាកាសធាតុរដ្ឋបាលថ្នាក់ក្រោមជាតិ (SCIF) | UNDP | 0 | 0 | 1,800 | 1,800 |
| ៩ | សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ASAC | 0 | 0 | 1,315 | 1,315 |
| | **សរុប** | | 0 | 300 | 33,016 | 33,316 |

# IV. ការគ្រប់គ្រង ផ.ស.ថ. ឆ្នាំ២០២៤

## ក. ការគ្រប់គ្រង និងការអនុវត្តសកម្មភាព

ការអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ ស្ថិតក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់ គ.ជ.អ.ប. ដែលមានលេខាធិការដ្ឋាន គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងការគ្រប់គ្រងការងារប្រចាំថ្ងៃ។

ស្ថាប័នអនុវត្ត ផ.ស.ថ. ឆ្នាំ២០២៤ រួមមានក្រសួង ស្ថាប័នសំខាន់ៗចំនួន២១ រាជធានី ខេត្តចំនួន ២៥ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន២០៨។ ការអនុវត្ត ផ.ស.ថ. របស់ស្ថាប័នអនុវត្តនីមួយៗធ្វើឡើងតាមរយៈសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយស្ថាប័នអនុវត្តទាំងនោះ។ សេចក្តីសម្រេចរួមរបស់រាជធានី ខេត្ត រួមបញ្ចូលទាំងសកម្មភាព និងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងដែលសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលរាជធានី ខេត្តក្នុងនាម គ.ជ.អ.ប. ចុះហត្ថលេខាលើសេចក្តីសម្រេចរួមរបស់ក្រុង ស្រុក។

នៅថ្នាក់ជាតិ គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ.) របស់ក្រសួង ស្ថាប័នដែលដឹកនាំដោយប្រធានស្ថាប័នទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការអនុវត្តសេចក្តីសម្រេចរួម។

នៅថ្នាក់ក្រោមជាតិ ការអនុវត្តសេចក្តីសម្រេចរួមស្ថិតក្រោមការដឹកនាំ និងការគ្រប់គ្រងរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ.) រាជធានី ខេត្ត និងគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រុង ស្រុក។ រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការជិតស្និទ្ធជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង និងការអនុវត្តសេចក្តីសម្រេចរួមរបស់ខ្លួន។

ក្នុងឆ្នាំ២០២៤ សកម្មភាពសំខាន់ៗមួយចំនួននឹងត្រូវរៀបចំ អនុវត្ត និងគ្រប់គ្រងតាមរយៈបែបផែននៃការគ្រប់គ្រងគម្រោង ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងធានាបាននូវការសម្រេចលទ្ធផលរំពឹងទុកទាំងនោះ។ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងអភិវឌ្ឍសមត្ថភាព និងគាំទ្រស្ថាប័នអនុវត្តទាំងអស់ក្នុងការរៀបចំ និងអនុវត្តសកម្មភាពតាមបែបផែនការជាគម្រោងនេះ។

សេចក្តីសម្រេចរួមនឹងអនុវត្តក្នុងភាពជាដៃគូជិតស្និទ្ធជាមួយសង្គមស៊ីវិល និងវិស័យឯកជននានា ដូចជាការលើកកម្ពស់គណនេយ្យភាពសង្គម និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សកម្មភាព អនុសកម្មភាព និងសូចនាករពាក់ព័ន្ធនានានៃ ផ.ស.ថ. របស់ គ.ជ.អ.ប. ត្រូវបានរៀបចំ និងបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ ផ.ស.ថ. (NAD) និងដាក់ឱ្យប្រើប្រាស់អនឡាញ (Online) ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. ក៏ដូចជាការធ្វើបច្ចុប្បន្នភាពនៃការអនុវត្តអនុសកម្មភាព និងថវិការបស់ ផ.ស.ថ. និងការរៀបចំរបាយការណ៍នានា។

## ខ. ការគ្រប់គ្រង និងការអនុវត្តថវិកា

ថវិកានៃ ផ.ស.ថ. របស់ស្ថាប័នអនុវត្តត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនានារបស់រាជរដ្ឋាភិបាល។ ក្នុងករណីស្ថាប័នអនុវត្តទទួលបានថវិកាគាំទ្របន្ថែមពីគម្រោង កម្មវិធីនានា ថវិការបស់ ផ.ស.ថ. ត្រូវអនុវត្តស្របតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់ គោលការណ៍ និងនីតិវិធីនានាដែល បានឯកភាពរវាងស្ថាប័នអនុវត្ត និងដៃគូអភិវឌ្ឍទាំងនោះ។

ជារៀងរាល់ខែ ស្ថាប័នអនុវត្ត ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា ដើម្បីផ្ញើជូន គ.ជ.អ.ប.

ជ្រាបជាព័ត៌មាន និងសម្រាប់រៀបចំ និងបូកសរុបជារបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំស្តីពីការអនុវត្ត ថវិការបស់ ផ.ស.ថ. និងដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងអនុម័ត។

## គ. ការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍នៃ ផ.ស.ថ.

ការត្រួតពិនិត្យ និងការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្ត ផ.ស.ថ. នឹងត្រូវធ្វើឡើង ផ្អែកតាមក្របខ័ណ្ឌលទ្ធផលដែលមានបរិយាយអំពីសូចនាករ និងចំណុចដៅនៃគោលបំណង គោលដៅ និង សកម្មភាពនីមួយៗដែលត្រូវសម្រេច ព្រមទាំងទិន្នន័យដើមគ្រា និងប្រភពទិន្នន័យដែលបញ្ជាក់អំពីភាព ជោគជ័យលទ្ធផលទាំងនោះ តាមចង្កោមសកម្មភាពនីមួយៗ។

### គ.១ ការត្រួតពិនិត្យ

គ.ជ.អ.ប. ទទួលខុសត្រូវក្នុងការត្រួតពិនិត្យអំពីវឌ្ឍនភាពនៃលទ្ធផល និងសមិទ្ធផលនៃការអនុវត្ត ផ.ស.ថ. តាមរយៈកិច្ចប្រជុំរបស់ គ.ជ.អ.ប. ដែលនឹងរៀបចំចំនួន២ដងក្នុងមួយឆ្នាំ។

នៅថ្នាក់ជាតិ អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ជាអ្នកទទួលខុសត្រូវ ក្នុងការតាមដាន និងត្រួតពិនិត្យជាប្រចាំលើវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. និងការរៀបចំរបាយការណ៍ដោយ ផ្អែកជាចម្បងលើប្រព័ន្ធ NAD និងការចុះតាមដាន និងគាំទ្រដោយផ្ទាល់នៅមូលដ្ឋាន។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ដើម្បី ពិនិត្យមើលពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្ត ផ.ស.ថ.។

ដោយឡែក ក្រុមការងារសវនកម្មផ្ទៃក្នុងនៃលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងធ្វើការត្រួតពិនិត្យការ អនុវត្ត ផ.ស.ថ. ពិសេសចំពោះសកម្មភាពដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍ និងរាយការណ៍ដោយផ្ទាល់ជូន ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.។

នៅតាមក្រសួង ស្ថាប័ននីមួយៗ គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវ ចាត់តាំងសមាជិករបស់ខ្លួនចំនួន១-២រូប ដើម្បីទទួលខុសត្រូវក្នុងការតាមដាន និងការត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. និងរាយការណ៍ជាប្រចាំជូនប្រធានក្រុមការងារអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាដែលជួប ប្រទះ។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័នត្រូវរៀបចំផែនការការងារអំពីការត្រួតពិនិត្យឱ្យបានច្បាស់លាស់ ដើម្បីចុះតាមដាន និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តមុខងារ ដែលបានផ្ទេរ។

នៅថ្នាក់ក្រោមជាតិ អនុប្រធានប្រចាំការនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ជាអ្នកទទួលខុសត្រូវក្នុងការតាមដានការអនុវត្ត ផ.ស.ថ. និងរាយការណ៍ជូនប្រធានគណៈ កម្មការជាប្រចាំអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្ត ផ.ស.ថ.។ ទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដែលជាលេខាធិការដ្ឋាន នៃគណៈកម្មការនេះត្រូវចាត់តាំងមន្ត្រីរបស់ខ្លួន ដើម្បីទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យជាប្រចាំ លើការអនុវត្ត ផ.ស.ថ.។ កិច្ចការនេះ ត្រូវអនុវត្តដោយសហការជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធនានាដូចជា ទីចាត់ការគ្រប់គ្រងធនធានមនុស្ស និងទីចាត់ការហិរញ្ញវត្ថុជាដើម។

ក្នុងអំឡុងពេលនៃការអនុវត្ត ស្ថាប័នអនុវត្តអាចធ្វើការពិនិត្យ និងកែសម្រួលសកម្មភាព និងថវិកា នៃ ផ.ស.ថ. តាមរយៈការធ្វើវិសោធនកម្មនៃសេចក្តីសម្រេចរួម ស្របតាមសេចក្តីណែនាំ និងនីតិវិធីនានារបស់ គ.ជ.អ.ប. និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

**គ.២ ការវាយតម្លៃ**

ជារៀងរាល់ឆ្នាំ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងរៀបចំការពិនិត្យមើលឡើងវិញអំពីសមិទ្ធផលនៃការអនុវត្ត ផ.ស.ថ. ដែលសម្រេចបានធៀបនឹងសមិទ្ធផល (ឬការផ្លាស់ប្តូរ) ដែលបានកំណត់ក្នុងឯកសារកម្មវិធីជាតិដំណាក់កាលទី២។ កិច្ចការនេះនឹងរៀបចំតាមរយៈកិច្ចដំណើរការដែលមានការចូលរួម និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមគោលដៅ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ជាមួយគ្នានេះដែរ សមិទ្ធផលនៃការអនុវត្ត ផ.ស.ថ. នឹងធ្វើការឆ្លុះបញ្ចាំងក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលរៀបចំឡើងជារៀងរាល់ឆ្នាំ។

នៅតាមស្ថាប័នអនុវត្តនីមួយៗ ជារៀងរាល់ឆ្នាំត្រូវរៀបចំការពិនិត្យមើលឡើងវិញផ្ទៃក្នុងប្រចាំឆ្នាំតាមរយៈកិច្ចប្រជុំ ឬសិក្ខាសាលា ឬតាមរយៈមធ្យោបាយសមស្របផ្សេងទៀត ដើម្បីពិនិត្យមើលពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្ត ផ.ស.ថ. របស់ខ្លួន ក៏ដូចជា ការលើកទិសដៅសម្រាប់ឆ្នាំបន្ទាប់។

ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងសម្របសម្រួលរៀបចំឱ្យមានការធ្វើសវនកម្មផ្ទៃក្រៅដែលអនុវត្តដោយក្រុមហ៊ុនសវនកម្មឯករាជ្យលើការអនុវត្តថវិកា ផ.ស.ថ. ដែលគាំទ្រដោយដៃគូអភិវឌ្ឍនានាផ្អែកតាមការឯកភាព និងកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍនីមួយៗ។

**គ.៣ ការរៀបចំរបាយការណ៍**

របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ដែលត្រូវរៀបចំ រួមមានរបាយការណ៍ប្រចាំឆមាស និងរបាយការណ៍ប្រចាំឆ្នាំ។

ចំពោះសកម្មភាពដែលគាំទ្រមូលនិធិដោយដៃគូអភិវឌ្ឍ ការរៀបចំរបាយការការណ៍ ត្រូវធ្វើឡើងផ្អែកតាមការឯកភាព និងកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍនីមួយៗ។

ក្នុងអំឡុងពេលនៃការអនុវត្ត ផ.ស.ថ. ជារៀងរាល់ខែ ស្ថាប័នអនុវត្តទាំងអស់ត្រូវធ្វើបច្ចុប្បន្នភាព និងរាយការណ៍ជាប្រចាំក្នុងប្រព័ន្ធ NAD អំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាព និងថវិកា រួមបញ្ចូលទាំង បញ្ហាប្រឈមនានាដែលជួបប្រទះក្នុងអំឡុងពេលអនុវត្ត។ ក្នុងករណីចាំបាច់ លេខាធិការដ្ឋាន គ.ជ.អ.ប. អាចស្នើសុំបន្ថែមពីស្ថាប័នអនុវត្តនូវព័ត៌មានជាក់លាក់មួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្ត ផ.ស.ថ.។

នៅចុងឆ្នាំនីមួយៗ ស្ថាប័នអនុវត្តត្រូវរៀបចំរបាយការណ៍បិទសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. និងស្ថាប័នអនុវត្ត ស្របតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប.។

# ឧបសម្ព័ន្ធទី១ ÷ តារាងក្របខ័ណ្ឌលទ្ធផលរួមនៃ ជ.ស.ជ. ឆ្នាំ២០២៤

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 1 | ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖<br>យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំគាក់តែង និងអនុវត្តនូវកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | | | | | | |
| 1.1 | យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | | | | | | |
| 1.1.1 | ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ | 1. ចំនួនកិច្ចប្រជុំ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | 2 | 2 | 1 | 1 |
| | | 2. ចំនួនសរុបលិខិតបទដ្ឋាន/ឯកសារដែលបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប. | ឯកសារ | 3 | 4 | 2 | 2 |
| 1.1.2 | ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព | 3. ចំនួនកិច្ចប្រជុំអនុគណៈកម្មាធិការ គ.ជ.អ.ប. ដែលបានរៀបចំ | កិច្ចប្រជុំ | | 6 | 3 | 3 |
| 1.1.3 | ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 4. រចនាសម្ព័ន្ធនៃអង្គភាពចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល | រចនាសម្ព័ន្ធ | សេចក្តីព្រាង | អនុម័ត | 1 | |
| | | 5. ចំនួនសរុបវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់បុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប. | វគ្គ | 4 | 4 | 2 | 2 |
| 1.1.4 | ការលើកកម្ពស់ប្រសិទ្ធភាពដឹកនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 6. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយក្រសួង ស្ថាប័ន | កិច្ចប្រជុំ | 40 | 48 | 24 | 24 |
| | | 7. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់រាជធានី ខេត្ត | កិច្ចប្រជុំ | 50 | 50 | 25 | 25 |
| | | 8. ចំនួនកិច្ចប្រជុំ គ.ដ.វ.វ. ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រុង ស្រុក | កិច្ចប្រជុំ | 388 | 388 | 194 | 194 |
| 1.1.5 | ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានា | 9. ចំនួនកិច្ចប្រជុំរវាងកម្មវិធីកំណែទម្រង់អភិបាលកិច្ចនានាដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 10. ផែនការសកម្មភាពរួមប្រចាំឆមាសដែលបានរៀបចំ | ផែនការ | 2 | 2 | 1 | 1 |
| 1.1.6 | ការរៀបចំវេទិការវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរយោបល់លើការអនុវត្តគោលនយោបាយនានា | 11. ការសិក្សាអំពីការរៀបចំវេទិកា ឬកិច្ចប្រជុំរវាងប្រធានក្រុមប្រឹក្សា និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | សិក្សា | | 1 | | 1 |
| 1.1.7 | ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានាប្រកបដោយភាពស្ថាបនា | 12. ចំនួនកិច្ចប្រជុំ TWG-SNDD ដែលបានរៀបចំ | កិច្ចប្រជុំ | 1 | 2 | 1 | 1 |
| 1.1.8 | ការពង្រឹងយន្តការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 13. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់រាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 300 | 300 | 150 | 150 |
| | | 14. ចំនួនកិច្ចប្រជុំ គ.ក.ស.ក. របស់ក្រុង ស្រុក ខណ្ឌដែលបានរៀបចំ | កិច្ចប្រជុំ | 2,496 | 2,496 | 1,248 | 1,248 |
| **1.2** | **ចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។** | | | | | | |
| 1.2.1 | ការកែលម្អ និងការពង្រឹងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 15. យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង ត្រូវបានពិនិត្យកែសម្រួល និងអនុម័ត | យុទ្ធសាស្ត្រ | | 1 | 1 | |
| 1.2.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង | 16. ចំនួនសរុបវេទិកា ឬកម្មវិធីផ្សព្វផ្សាយអំពីចក្ខុវិស័យ គោលដៅ និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំ | វេទិកា | 12 | 12 | 6 | 6 |
| | | 17. ចំនួនសរុបឯកសារព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្សព្វផ្សាយ | ឯកសារព័ត៌មាន | 5 | 5 | 2 | 3 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 1.3 | កម្មវិធីជាតិដំណាក់កាលទី២ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | | | | | | |
| 1.3.2 | ការរៀបចំ និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. | 18. ផ.ស.ថ. ឆ្នាំ២០២៤ ត្រូវបានរៀបចំ និងអនុម័ត | ផ.ស.ថ. | 1 | 1 | 1 | |
| | | 19. ភាគរយសរុបសកម្មភាពអាទិភាពនៃ ផ.ស.ថ. ឆ្នាំ២០២៤ ដែលសម្រេចបាន | ភាគរយ | 80% | 80% | 40% | 40% |
| | | 20. សេចក្តីព្រាង ផ.ស.ថ. ឆ្នាំ២០២៥ ត្រូវបានរៀបចំ | ផ.ស.ថ. | | 1 | | 1 |
| | | 21. ចំនួនសរុបនៃសេចក្តីសម្រេចរួមដែលបានរៀបចំ និងអនុម័ត | សេចក្តីសម្រេចរួម | 45 | 46 | 46 | |
| 1.3.3 | ការរៀបចំ និងដាក់បញ្ចូលកិច្ចការ ឬគម្រោងនានានៃកជទី២ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ស្ថាប័នអនុវត្តនីមួយៗ | 22. ចំនួនក្រសួង ស្ថាប័នបានបញ្ចូលសកម្មភាពនៃ ផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 21 | 21 | 21 | |
| | | 23. ចំនួនរដ្ឋបាលរាជធានី ខេត្តបានបញ្ចូលសកម្មភាពនៃ ផអ៥ទី១ក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន | ផែនការ | 25 | 25 | 25 | |
| 1.3.6 | ការសម្របសម្រួល ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តកជទី២ | 24. ការអង្កេតអភិបាលកិច្ច | ការអង្កេត | | 1 | | 1 |
| | | 25. ការវាយតម្លៃលើការអនុវត្តកជទី១ | ការវាយតម្លៃ | | 1 | | 1 |
| | | 26. របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផ.ស.ថ. របស់ គ.ជ.អ.ប. | របាយការណ៍ | 2 | 1 | 1 | 1 |
| | | 27. សវនកម្មយេនឌ័រ | ការអង្កេត | | 1 | | 1 |
| 1.5 | ការចូលរួមរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការកំណែទម្រង់ត្រូវបានលើកកម្ពស់ | | | | | | |
| 1.5.1 | ការពង្រឹងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 28. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |
| | | 29. ចំនួនកិច្ចប្រជុំអង្គអភិបាលកិច្ចរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋានដែលបានរៀបចំ | កិច្ចប្រជុំ | 4 | 4 | 2 | 2 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 30. ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ផែនការ | | 1 | | 1 |
| | | 31. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សមាជិកសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត | វគ្គ | 3 | 4 | 2 | 2 |
| | | 32. ចំនួនសរុបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន | វគ្គ | 3 | 4 | 2 | 2 |
| 1.5.2 | ការសិក្សាអំពីជម្រើសនៃការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 33. ការសិក្សាអំពីជម្រើសនានាត្រូវបានអនុវត្ត | ការសិក្សា | | 1 | | 1 |
| 1.5.4 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយនានាពាក់ព័ន្ធនឹងកំណែទម្រង់ | 34. ការសិក្សា និងរៀបចំយុទ្ធសាស្ត្រនៃការចូលរួមរបស់អង្គការសង្គមស៊ីវិល | ការសិក្សា | | 1 | | 1 |
| | | 35. ចំនួនកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលលើការរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងកំណែទម្រង់ | កិច្ចប្រជុំ | 2 | 2 | 1 | 1 |
| 2 | **រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ៖**<br>**រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយចំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ** | | | | | | |
| 2.1 | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវបានពង្រឹង កែសម្រួល និងប្រតិបត្តិការជារដ្ឋបាលមូលដ្ឋាន និងស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ** | | | | | | |
| 2.1.1 | ការពង្រឹងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង ស្រុក | 36. ភាគរយសរុបនៃក្រុង ស្រុក ខណ្ឌដែលទទួលការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារដែលបានផ្ទេរ | ភាគរយ | 20% | 20% | 10% | 10% |
| | | 37. មុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសត្រូវបានកំណត់ | លិខិតបទដ្ឋាន | 1 | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 38. ភាគរយសរុបនៃមុខងាររបស់រដ្ឋបាលក្រុង ស្រុក ដែលមានសេចក្ដីណែនាំបច្ចេកទេសសម្រាប់អនុវត្ត | ភាគរយ | ៦០% | ៧០% | ៦០% | ១០% |
| | | 39. ទិន្នន័យដើមគ្រាសម្រាប់មុខងារអប់រំត្រូវបានរៀបចំ | របាយការណ៍ | | 1 | 1 | |
| | | 40. ការសិក្សាវាយតម្លៃលើការអនុវត្តមុខងារសុខាភិបាល | របាយការណ៍ | | 1 | 1 | |
| | | 41. ការសិក្សាអំពីលទ្ធភាពបង្កើតការិយាល័យសុខាភិបាលនៅថ្នាក់ក្រុង ស្រុក | របាយការណ៍ | | 1 | | 1 |
| 2.1.2 | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាលឃុំ សង្កាត់ | 42. ភាគរយឃុំ សង្កាត់ដែលទទួលបានការគាំទ្រ និងអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំក្នុងការអនុវត្តមុខងារ | ភាគរយ | 5% | 5% | 2.5% | 2.5%? |
| | | 43. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយរាជធានី ខេត្តក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | 100% |
| | | 44. ភាគរយឃុំ សង្កាត់ដែលទទួលការគាំទ្រដោយក្រុង ស្រុកក្នុងការអនុវត្តមុខងារ | ភាគរយ | 100% | 100% | 100% | 100% |
| 2.1.3 | ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន | 45. ការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យដើម្បីប្រែក្លាយស្រុកទៅជាក្រុង និងឃុំទៅជាសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | | 1 | 1 | |
| | | 46. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង និងសង្កាត់ដែលស្ថិតក្នុងតំបន់ទីប្រជុំជន | របាយការណ៍ | | 1 | | 1 |
| 2.1.4 | ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធមុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំ ស្ថិតនៅក្នុងតំបន់ជនបទ | 47. ការសិក្សា និងពិនិត្យកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលស្រុក និងឃុំដែលស្ថិតក្នុងតំបន់ជនបទ | របាយការណ៍ | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| **2.2** | **រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលខេត្តត្រូវបានសិក្សា និងកំណត់អំពីជម្រើសសមស្របនានាស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ និងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព** | | | | | | |
| 2.2.1 | ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្ត | 48. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរបស់រដ្ឋបាលខេត្ត | របាយការណ៍ | | 1 | | 1 |
| 2.3.1 | ការសិក្សាជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានី | 49. ការសិក្សាអំពីជម្រើសនានានៃការរៀបចំរដ្ឋបាលរាជធានី | របាយការណ៍ | | 1 | | 1 |
| **2.4** | **ទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង កែលម្អ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.4.4 | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | 50. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត | វេទិកា | 100 | 100 | 50 | 50 |
| | | 51. ចំនួនសរុបនៃវេទិកាសាធារណៈដែលបានរៀបចំដោយរដ្ឋបាលក្រុង ស្រុក | វេទិកា | 776 | 776 | 388 | 388 |
| **2.5** | **សមត្ថភាពដឹកនាំរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង** | | | | | | |
| 2.5.3 | ការរៀបចំកញ្ចប់ថវិកាដាក់លាក់សម្រាប់គាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 52. ការសិក្សាអំពីលទ្ធភាព និងការរៀបចំកញ្ចប់ថវិកាគាំទ្រដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | 1 | |
| **2.6** | **ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាបាននូវជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 2.6.1 | ការពង្រឹងយន្តការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ | 53. ការសិក្សាអំពីជម្រើសនានាក្នុងការបង្កើតយន្តការផ្ដល់ព័ត៌មាននៅរដ្ឋបាលថ្នាក់ក្រោមជាតិជូនប្រជាពលរដ្ឋ | របាយការណ៍ | 1 | 1 | | 1 |
| | | 54. ភាគរយសរុបនៃឃុំ សង្កាត់ដែលអនុវត្តការងារគណនេយ្យភាពសង្គម | ភាគរយ | 93% | 93% | 93% | 93% |
| | | 55. ការសិក្សា និងរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ត្រូវបានរៀបចំ | របាយការណ៍ | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 56. ភាគរយសរុបនៃតំបន់គោលដៅការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រុង ស្រុក ខណ្ឌលើសេវាតាមការិយាល័យច្រកចេញចូលតែមួយ | ភាគរយ | 17% | 17% | 17% | 17% |
| 2.6.2 | ការពង្រឹងយន្តការសម្រាប់ទទួលការដាក់សំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ | 57. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវបានរៀបចំ | វគ្គ | 1 | 1 | 1 | |
| | | 58. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | បណ្តឹង | 80% | 80% | 80% | 80% |
| | | 59. ការអភិវឌ្ឍសមត្ថភាពដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | វគ្គ | 1 | 1 | 1 | |
| | | 60. ភាគរយបណ្តឹងរបស់ប្រជាពលរដ្ឋត្រូវបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ | បណ្តឹង | 80% | 80% | 80% | 80% |
| 2.6.3 | ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងកិច្ចដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ | 61. ភាគរយរដ្ឋបាលរាជធានី ខេត្ត ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 50% | 50% | 50% | 50% |
| | | 62. ភាគរយរដ្ឋបាលក្រុង ស្រុក ដែលបានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល | ភាគរយ | 20% | 20% | 20% | 20% |
| **2.7** | **ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើទំនើបកម្មតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល** | | | | | | |
| 2.7.1 | ការពង្រឹង និងពង្រីកលទ្ធភាពក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | 63. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបានតំណភ្ជាប់សេវាអ៊ីនធឺណិត | ភាគរយ | 40% | 60% | 50% | 60% |
| | | 64. ប្រព័ន្ធទិន្នន័យនានារបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល ( ISAF M&E Database, NAD, PID... ) | ប្រព័ន្ធ | 5 | 5 | 2 | 3 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 2.7.2 | ការរៀបចំ និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 65. ការសិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNA-MIS) | របាយការណ៍ | | 1 | | 1 |
| | | 66. ការសិក្សាអំពីប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិត្រូវបានអនុវត្ត | របាយការណ៍ | 1 | 1 | | 1 |
| 2.7.3 | ការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | 67. ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់គេហទំព័របណ្ដាញសង្គម និងប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ដើម្បីផ្សព្វផ្សាយ និងទទួលព័ត៌មានពាក់ព័ន្ធនានា | ភាគរយ | 20% | 50% | 50% | 50% |
| | | 68. ភាគរយរាជធានីខេត្ត បានរៀបចំ និងផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | ភាគរយ | 70% | 70% | 70% | 70% |
| 2.8 | **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងយន្តការអធិការកិច្ចផ្ទៃក្រៅដែលមានលក្ខណៈជាប្រព័ន្ធមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ កែសម្រួល និងដាក់ឱ្យអនុវត្ត** | | | | | | |
| 2.8.1 | ការពង្រឹងយន្តការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 69. ការសិក្សាអំពីលទ្ធភាពនៃការបង្កើតអង្គភាពត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | | 1 | 1 | |
| | | 70. បែបបទ នីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវបានរៀបចំ | សេចក្ដីណែនាំ | | 1 | | 1 |
| 3 | **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្ដីភាព និងមានសមត្ថភាពជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ** | | | | | | |
| 3.1 | **អង្គមន្ត្រីរាជការស៊ីវិលត្រូវបានពិនិត្យ រៀបចំឡើងវិញ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.1.1 | ការពិនិត្យ និងកែសម្រួលអង្គមន្ត្រីរាជការ | 71. ការសិក្សា និងរៀបចំលិខិតបទដ្ឋាននានាស្តីពីអង្គមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 72. ការសិក្សាអំពីការរៀបចំក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ ឱ្យសមស្របនឹងមុខតំណែង និងការទទួលខុសត្រូវ របស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| **3.2** | **ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.2.1 | ការរៀបចំការពិពណ៌នាមុខតំណែងរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 73. សេចក្តីណែនាំស្តីពីការពិពណ៌នាអំពីមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈសម្រាប់អង្គភាពនីមួយៗនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ | សេចក្តីណែនាំ | | អនុម័ត | | 1 |
| 3.2.2 | ការពង្រឹងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 74. គោលការណ៍ណែនាំស្តីពីការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | គោលការណ៍ | | 1 | | 1 |
| 3.2.4 | ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 75. លិខិតបទដ្ឋានស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | អនុម័ត | | 1 |
| 3.2.5 | ការលើកកម្ពស់ការតាមដាន និងការវាយតម្លៃលើការបំពេញការងារ | 76. ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងអនុម័ត | ប្រព័ន្ធ | សេចក្តីព្រាង | អនុម័ត | | 1 |
| **3.3** | **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបុគ្គលិកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.3.1 | ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ | 77. ការសិក្សា និងការរៀបចំឯកសារទស្សនទានអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ឯកសារទស្សនទាន | | 1 | 1 | |
| **3.4** | **តម្រូវការធនធានមនុស្សទាំងចំនួនបុគ្គលិក និងទាំងជំនាញវិជ្ជាជីវៈត្រូវបានវាយតម្លៃ និងកំណត់ច្បាស់លាស់** | | | | | | |
| 3.4.1 | ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈ | 78. សេចក្តីណែនាំស្តីពីការវាយតម្លៃតម្រូវការធនធានមនុស្សត្រូវបានរៀបចំ | សេចក្តីណែនាំ | | សេចក្តីព្រាង | | 1 |
| 3.4.2 | ការពង្រឹងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | 79. ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការបុគ្គលិក | វគ្គ | | អនុវត្ត | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3.4.3 | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 80. ភាគរយរដ្ឋបាលថ្នាក់រាជធានី ខេត្តបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | | 100% | | 100% |
| | | 81. ភាគរយរដ្ឋបាលថ្នាក់ក្រុង ស្រុកបានរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ | ភាគរយ | | 100% | | 100% |
| 3.5.1 | ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 82. ការសិក្សាអំពីជម្រើសនានាសម្រាប់ផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | របាយការណ៍ | | 1 | | 1 |
| **3.5** | **គោលនយោបាយលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.5.4 | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | 83. ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត ផ្សព្វផ្សាយ និងអនុវត្ត | ផែនការ | សេចក្តីព្រាង | អនុម័ត | 1 | |
| | | 84. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត | ភាគរយ | 27.51% | 27.51% | | 27.51% |
| | | 85. ភាគរយស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ | ភាគរយ | 23.58% | 23.58% | | 23.58% |
| **3.6** | **ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹង និងកំណត់យ៉ាងច្បាស់លាស់** | | | | | | |
| 3.6.1 | ការពិនិត្យ និងការកែសម្រួលនូវឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 86. សេចក្តីណែនាំស្តីពីឧបករណ៍ និងវិធីសាស្ត្រនៃការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពត្រូវបានពិនិត្យ និងកែសម្រួល | សេចក្តីណែនាំ | | 1 | | 1 |
| 3.6.2 | ការពង្រឹងសមត្ថភាពដល់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | 87. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់អង្គភាពអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តអំពីការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាព | វគ្គ | | 1 | | 1 |
| 3.6.3 | ការរៀបចំការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | 88. របាយការណ៍វាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត | របាយការណ៍ | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 3.6.4 | ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមតម្រូវការអភិវឌ្ឍសមត្ថភាព | 89. ភាគរយរដ្ឋបាលរាជធានី ខេត្តដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | | 100% | | 100% |
| | | 90. ភាគរយរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានរៀបចំផែនការអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំរបស់ខ្លួន | ភាគរយ | | 90% | | 90% |
| | | 91. ភាគរយនៃសកម្មភាពអភិវឌ្ឍសមត្ថភាពដែលបានគ្រោងក្នុងផែនការអភិវឌ្ឍសមត្ថភាពត្រូវបានអនុវត្ត | ភាគរយ | | 80% | 40% | 40% |
| **3.7** | **ស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានពង្រឹងការអនុវត្តពេញលេញ និងស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.7.1 | ការជ្រើសរើស និងការពង្រឹងសមត្ថភាពបុគ្គលិកនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន | 92. ភាគរយអគារនៃសាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវបានសាងសង់ | ភាគរយ | | 60% | 30% | 30% |
| | | 93. ចំនួនវគ្គបណ្តុះបណ្តាលដែលបានរៀបចំសម្រាប់គ្រូបណ្តុះបណ្តាល និងបុគ្គលិករបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន | វគ្គ | 4 | 4 | 2 | 2 |
| 3.7.3 | ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសម្រាប់ក្រុមគោលដៅផ្សេងៗ | 94. ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានរៀបចំ | វគ្គ | 35 | 35 | 15 | 20 |
| **3.8** | **កម្មវិធីសិក្សាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត** | | | | | | |
| 3.8.2 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលនានា | 95. លិខិតបទដ្ឋានស្តីពីការរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | លិខិតបទដ្ឋាន | | 1 | | 1 |
| 3.8.3 | ការរៀបចំ ការពិនិត្យកែសម្រួល និងការធ្វើបច្ចុប្បន្នភាពលើឯកសារសម្ភារៈបណ្តុះបណ្តាលសម្រាប់កម្មវិធីសិក្សានានា | 96. ចំនួនសៀវភៅគោលត្រូវបានរៀបចំ | ក្បាល | 5 | 4 | | 4 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 4 | **ទិមដ្ឋការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។** | | | | | | |
| 4.1 | **កិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ និងបង្កើន ដោយផ្អែកលើទិតលក្ខណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ** | | | | | | |
| 4.1.1 | ការបន្សីគ្នារវាងកិច្ចដំណើរការកសាងផែនការ និងការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 97. ភាគរយគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគាំទ្រទៅលើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន | ភាគរយ | | 100% | 100% | 100% |
| 4.1.4 | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 98. ប្រព័ន្ធទិន្នន័យស្តីពីព័ត៌មានគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SPD) ត្រូវបានពិនិត្យ និងកែសម្រួល | ទិន្នន័យ | បានរៀបចំកែសម្រួល | 1 | 1 | |
| | | 99. ប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់(CDB) ឆ្នាំ២០២៣ ត្រូវបានប្រមូល ផលិត និងចែករំលែក | ទិន្នន័យ | | 1 | 1 | |
| | | 100. ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីមន្ទីរផែនការអំពីដំណើរការ និងវិធីសាស្ត្រកសាងផែនការនៅថ្នាក់ក្រោមជាតិ និងវិធីសាស្ត្រកែច្នៃ វិភាគ និងផលិតឯកសារព័ត៌មាន និងទិន្នន័យនានា | វគ្គ | 2 | 3 | 1 | 2 |
| 4.2 | **ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អដោយមានការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទិសដៅនៃយុទ្ធសាស្ត្រកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 4.2.1 | ការបន្តការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៩-២០២៥) | 101. ចំនួនរដ្ឋបាលរាជធានី ខេត្ត ដែលបានអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | រាជធានី ខេត្ត | 25 | 25 | 25 | 25 |
| | | 102. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត | លិខិតបទដ្ឋាន | | 1 | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 103. បែបផែនថ្មីពាក់ព័ន្ធនឹងមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងការទូទាត់ថវិការបស់ថ្នាក់ក្រុង ស្រុកដែលត្រូវបានធ្វើប្រតិភូកម្មទៅឱ្យតេនាគារខេត្ត | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 104. ក្របខ័ណ្ឌរួមស្តីពីការធ្វើរបាយការណ៍ និងការត្រួតពិនិត្យតាមដានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 105. ក្របខ័ណ្ឌរួមមួយស្តីពីការវាយតម្លៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | | 1 |
| **4.3** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | |
| 4.3.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធដែលមានស្រាប់ | 106. លិខិតបទដ្ឋានស្តីពីការព្យាករណ៍ ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើការប្រមូលចំណូលសារពើពន្ធពីប្រភេទពន្ធដែលមានស្រាប់របស់រាជធានី ខេត្តត្រូវបានរៀបចំ និងអនុវត្ត | លិខិតបទដ្ឋាន | | 1 | 1 | |
| | | 107. ចំណូលសារពើពន្ធរបស់រាជធានី ខេត្តមានការកើនឡើងធៀបនឹងឆ្នាំ២០២៣ | ចំណូល | 530លានដុល្លារ | កើនឡើង | | 1 |
| 4.3.2 | ការចែករំលែកចំណូលសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ | 108. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក | ភាគរយ | 4% | 4% | 4% | 4% |
| | | 109. ចំនួនភាគរយនៃអត្រាចំណូលចែករំលែកពីចំណូលសារពើពន្ធរបស់រដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលឃុំ សង្កាត់ | ភាគរយ | 5% | 6% | 6% | 6% |
| **4.4** | **ការបង្កើនប្រភពចំណូលមូលដ្ឋានជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានមកពីចំណូលមិនមែនសារពើពន្ធត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត** | | | | | | |
| 4.4.2 | ការលើកកម្ពស់ការប្រមូល និងការគ្រប់គ្រងកម្រៃ ឬឈ្នួលសេវា | 110. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | ប្រព័ន្ធ | អនុវត្ត | អនុវត្ត | | 1 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 111. ភាគរយនៃការទូទាត់តាមប្រព័ន្ធឌីជីថលសម្រាប់អង្គភាព/ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ភាគរយ | សាកល្បង | សេវាចំនួន ១០% បានអនុវត្ត | | 1 |
| | | 112. ការសិក្សាអំពីជម្រើសនានានៃការប្រើប្រាស់ចំណូលដែលទទួលបានកម្រៃពីអ្នកប្រើប្រាស់សេវាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| 4.5 | ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមផែនការទ្បស់លាស់ | | | | | | |
| 4.5.1 | ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 113. ទ្រព្យសម្បត្តិរដ្ឋត្រូវបានផ្ទេរពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមមុខងារដែលបានផ្ទេរ | ការផ្ទេរ | | អនុវត្ត | | 1 |
| | | 114. សេចក្តីណែនាំស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | សេចក្តីណែនាំ | | 1 | 1 | |
| | | 115. ការបែងចែកចំណូលពីទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត | ការបែងចែក | | អនុវត្ត | | 1 |
| | | 116. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលរាជធានី ខេត្តត្រូវបានពង្រឹងការអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | | 1 |
| | | 117. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅរដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ប្រព័ន្ធ | | អនុវត្ត | | 1 |
| 4.6 | មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់ទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានវិភាជទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យប្រកបដោយសមធម៌ ព្រមទាំងត្រូវបានបង្កើនទំហំជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ក្រុង ស្រុក) ក្នុងការអនុវត្តមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ | | | | | | |
| 4.6.1 | ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក | 118. អត្រាផ្ទេរធនធានពីថវិការដ្ឋទៅឱ្យមូលនិធិក្រុង ស្រុក | អត្រា | 1.5 | 1.6 | 1.6 | 1.6 |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| | | 119. ការសិក្សាអំពីប្រភេទចំណូលមិនមែនសារពើពន្ធជាក់លាក់មួយចំនួនដែលត្រូវបន្ថែមទៅឱ្យរដ្ឋបាលក្រុង ស្រុក | របាយការណ៍ | | 1 | | 1 |
| 4.6.2 | ការពង្រឹងនូវប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 120. ការសិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបែងចែកមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋាន | | រៀបចំ | | 1 |
| 4.6.3 | ការលើកកម្ពស់សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌសម្រាប់គម្រោងសេវាកម្មនានា | 121. លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីអនុវត្តគម្រោងសេវាសង្គម អនាម័យ និងបរិស្ថាន | លិខិតបទដ្ឋាន | | 1 | | 1 |
| **4.7** | **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌត្រូវបានកំណត់នូវទំហំដែលមានលក្ខណៈសមស្រប និងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចនានាដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 4.7.1 | ការលើកកម្ពស់ការអនុវត្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌក្នុងក្របខ័ណ្ឌដែលមានបច្ចុប្បន្ន ព្រមទាំងរៀបចំ និងកែលម្អក្របខ័ណ្ឌផ្ដល់ហិរញ្ញប្បទានដល់មុខងារជាកាតព្វកិច្ចឱ្យកាន់តែប្រសើរឡើង | 122. ការសិក្សាលើការរៀបចំការដាក់បញ្ចូលធនធានហិរញ្ញវត្ថុផ្ទេរមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារទៅក្នុងគម្រោងថវិកាឯកភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការសិក្សា | | រៀបចំ | | 1 |
| **4.8** | **ក្របខ័ណ្ឌសម្រាប់ផ្ដល់ហិរញ្ញប្បទានការវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំឡាស់លាស់មួយត្រូវបានបង្កើត និងពង្រឹងការអនុវត្ត** | | | | | | |
| 4.8.1 | ការពិនិត្យមើលឡើងវិញ និងការពង្រឹងការគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | 123. ការសិក្សា និងវាយតម្លៃលើការអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ | របាយការណ៍ | | 1 | | 1 |
| | | 124. គោលការណ៍ណែនាំស្ដីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកត្រូវពិនិត្យ និងកែសម្រួល | គោលការណ៍ | | 1 | | 1 |
| 4.8.3 | ការសិក្សា និងរៀបចំក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព និងកញ្ចប់ថវិកាពិសេស | 125. លិខិតបទដ្ឋានសម្រាប់បង្កើតយន្តការមូលនិធិភាតរភាពត្រូវបានរៀបចំ | លិខិតបទដ្ឋាន | | 1 | 1 | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 4.9 | ក្របខ័ណ្ឌសម្រាប់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព | | | | | | |
| 4.9.1 | ការសិក្សា និងរៀបចំនូវក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | 126. សិក្សា និងរៀបចំអំពីក្របខ័ណ្ឌភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជន | របាយការណ៍ | | 1 | | 1 |
| | | 127. នីតិវិធីសម្រាប់ការគ្រប់គ្រង និងការចុះបញ្ជីវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្ដីណែនាំ | | 1 | 1 | |
| 5 | ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ÷ រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដារសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះសម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | | | | | | |
| 5.1 | ការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងកែលម្អឱ្យកាន់តែមានប្រសិទ្ធភាព | | | | | | |
| 5.1.1 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាកាតព្វកិច្ច | 128. មេរៀនបទពិសោធស្តីពីការអនុវត្តមុខងារជាកាតព្វកិច្ចត្រូវបានរៀបចំ | ករណីសិក្សា | | 1 | | 1 |
| | | 129. ចំនួនភាគរយសរុបនៃមុខងារជាកាតព្វកិច្ចដែលមានសេចក្ដីណែនាំបច្ចេកទេសស្តីពីបែបបទ នីតិវិធី និងស្តង់ដានៃការអនុវត្តមុខងារកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ | ភាគរយ | 70% | 90% | 80% | 90% |
| 5.1.2 | ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងារជាជម្រើស | 130. នីតិវិធីអនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | បានសិក្សា | បានកែសម្រួល | 1 | |
| | | 131. នីតិវិធីអនុវត្តមុខងារជាជម្រើសសម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួល | ការសិក្សា | បានសិក្សា | បានកែសម្រួល | 1 | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| **5.2** | **យន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពិនិត្យ កែលម្អ និងពង្រឹងការអនុវត្តដើម្បីធានាថាការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល឵ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | | | | |
| 5.2.1 | ការកែសម្រួលរចនាសម្ព័ន្ធ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត | 132. បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 133. សេចក្តីណែនាំបច្ចេកទេសស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគនៅថ្នាក់រាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | សេចក្តីណែនាំ | | 1 | 1 | |
| 5.2.3 | ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ | 134. ការផ្តល់សេវាក្នុងវិស័យមួយចំនួនបានផ្តល់តាមប្រព័ន្ធអនឡាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បង | ការផ្តល់សេវា | 3 | 5 | | 1 |
| **5.4** | **ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានា ត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | |
| 5.4.1 | ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 135. សេចក្តីណែនាំស្តីពីការរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | សេចក្តីណែនាំ | | 1 | | 1 |
| 5.4.2 | ការកំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវាដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ | 136. ឯកសារបទដ្ឋានបច្ចេកទេសសម្រាប់ការផ្តល់សេវា និងការវិនិយោគដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ | សៀវភៅណែនាំ | សេចក្តីព្រាង | អនុម័ត | 1 | |
| 5.4.3 | ការពង្រឹងការប្រើប្រាស់ទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 137. ការសិក្សា និងរៀបចំទិន្នន័យអាកាសធាតុ សន្ទស្សន៍ភាពងាយរងគ្រោះ និងទិន្នន័យនៃការវិភាគការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផែនទីភូមិសាស្ត្រប្រព័ន្ធព័ត៌មានវិទ្យាស្តីពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំ និងអនុវត្ត | របាយការណ៍ | បានសិក្សា | អនុវត្ត | 1 | |

| កូដ | សមាសភាគ លទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព | សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា ឆ្នាំ២០២៣ | ចំណុចដៅឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|---|
| | | | | | ប្រចាំឆ្នាំ | ឆមាសទី១ | ឆមាសទី២ |
| 5.4.4 | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | 138. លិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិដោយបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ជំងឺឆ្លងកាចសាហាវ សមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងសេវាសង្គម ត្រូវបានពិនិត្យ និងកែសម្រួល | លិខិតបទដ្ឋាន | | 1 | | 1 |
| | | 139. ចំនួនភាគរយនៃគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្តដោយផ្តោតលើការបង្កើតភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានានៅក្នុងសហគមន៍មូលដ្ឋាន | ភាគរយ | 20% | 20% | 10% | 10% |

# ឧបសម្ព័ន្ធទី២ ៖ តារាងសកម្មភាពលម្អិតនៃ ផ.ស.ថ. ឆ្នាំ២០២៤

| កូដ | លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព និងសកម្មភាពលម្អិត | ថវិកា | ឆមាស ១ | ឆមាស ២ | ស្ថាប័នទទួលខុសត្រូវអនុវត្ត |
|---|---|---|---|---|---|
| 1 | **ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់៖**<br>**យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានានៅក្នុងការរៀបចំគាំទ្រ និងអនុវត្តន៍កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព** | 12,960,849,000 | | | |
| 1.1 | **យន្តការដឹកនាំកំណែទម្រង់ត្រូវបានពង្រឹងយ៉ាងរឹងមាំ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន** | 3,086,265,000 | | | |
| **1.1.1** | **ការបន្តពង្រឹងតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់** | 52,000,000 | | | |
| 1.1.1.1 | រៀបចំកិច្ចប្រជុំ គ.ជ.អ.ប. ដើម្បីដឹកនាំ ពិភាក្សា និងសម្របសម្រួលកំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការ | 52,000,000 | x | x | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| **1.1.2** | **ការបន្តពង្រឹងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក្នុងការបំពេញភារកិច្ចឱ្យមានប្រសិទ្ធភាព** | 110,500,000 | | | |
| 1.1.2.1 | រៀបចំអង្គភាព ឬក្រុមការងារដើម្បីជួយដល់អនុគណៈកម្មាធិការសាមីនីមួយៗក្នុងការបំពេញការងារប្រចាំថ្ងៃ | 20,500,000 | x | x | ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.1.2.2 | រៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗ នៃ គ.ជ.អ.ប. | 30,000,000 | x | x | ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. |
| 1.1.2.3 | ការសិក្សាស្រាវជ្រាវ និងការតាមដាន ត្រួតពិនិត្យរបស់អនុគណៈកម្មការរបស់ គ.ជ.អ.ប. | 60,000,000 | x | x | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| **1.1.3** | **ការពង្រឹងសមត្ថភាព តួនាទី និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.** | 141,000,000 | | | |
| 1.1.3.1 | ពិនិត្យមើលឡើងវិញ និងកែសម្រួលរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. | 30,000,000 | | x | លេខាធិការដ្ឋាន គ.ជ.អ.ប. |

| | | | | | |
|---|---|---|---|---|---|
| 1.1.3.2 | រៀបចំនិងដាក់ឱ្យដំណើរការនូវយន្តការចាំបាច់នានារបស់ គ.ជ.អ.ប. | 30,000,000 | x | x | លេខាធិការដ្ឋាន គ.ជ.អ.ប. |
